**Article1 :** To appoint His Excellency **Chung, Sye Kyun** as an Economic advisor to Samdech Akka Moha Sena Padei Techo **Hun Sen** Prime Minister of the Kingdom of Cambodia.

**Article2 :** Minister of the Council of the Ministers, Minister of Economy and Finance, Secretary of State of the public function, all relevant Ministries/Institutions and Person as described in article 1 to implement this decision effectively from the date of signature herein.

Phnom Penh, April 4, 2011

**Prime Minister**

**Samdech Akka Moha Sena Padei Techo Hun Sen**

CC
- Cabinet of Royal Palace
- General Secretary of the Senate
- General Secretary of the National Assembly
- General Secretary of the Royal Government
- Cabinet of Samdech Prime Minister
- Cabinets of Deputy Prime Minister
- As article 2
- Office Journal
- Archives

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ធ៧-០១១-១១០ ប្រ.ក

# ប្រកាស

## ស្ដីពី

## ការកែសម្រួលប្រកាសស្ដីពីបង្កើតគណៈកម្មការគោលនយោបាយរូបិយវត្ថុ

## ទេសាភិបាលធនាគារជាតិនៃកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី ២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៦ ចុះថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីវិសោធនកម្មមាត្រា ១៤ និងមាត្រា ៥៧ នៃច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០៨/៥២៦ ចុះថ្ងៃទី ១៣ ខែឧសភា ឆ្នាំ២០០៨ ស្ដីពីការតែងតាំងឯកឧត្ដម **ជា ចាន់តូ** ជាអគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា មានឋានៈស្មើទេសរដ្ឋមន្ត្រី
- យោងតាមប្រកាសលេខ ធ៨៩៨-៣៨៥ ប្រ.ក ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៨ ស្ដីពីរចនាសម្ព័ន្ធរបស់ធនាគារជាតិនៃកម្ពុជា និងមុខងារ-ភារកិច្ចរបស់បណ្ដាអង្គភាពក្រោមឱវាទ
- យោងតាមប្រកាសលេខ ធ១-០១០-១៩៤ ប្រ.ក ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១០ ស្ដីពីការកែសម្រួលប្រការ៣ ប្រការ៤ ប្រការ៥ ប្រការ១២ និងប្រការ១៣ នៃប្រកាសស្ដីពីរចនាសម្ព័ន្ធរបស់ធនាគារជាតិនៃកម្ពុជា និងមុខងារភារកិច្ចរបស់បណ្ដាអង្គភាពក្រោមឱវាទ
- យោងតាមសំណើររបស់អគ្គនាយកដ្ឋានបច្ចេកទេស

## ស ម្រេ ច

**ប្រការមួយ.-**

កែសម្រួលប្រកាសលេខ ធ៦-០៨-០០២ ប្រ.ក. ចុះថ្ងៃទី២ ខែមករា ឆ្នាំ២០០៨ ស្ដីពីការបង្កើតគណៈកម្មការគោលនយោបាយរូបិយវត្ថុ ដែលក្នុងប្រការជាបន្តបន្ទាប់ហៅថា «គណៈកម្មការ» ដូចតទៅ ៖

**ប្រការពីរថ្មី.-**

គណៈកម្មការរួមមានសមាសភាព ៩ រូប ៖

| | |
|---|---|
| ១. ទេសាភិបាល | ប្រធាន |
| ២. ទេសាភិបាលរង | អនុប្រធាន |
| ៣. អគ្គលេខាធិការ | សមាជិក |
| ៤. អគ្គនាយក | សមាជិក |
| ៥. ប្រធាននាយកដ្ឋានស្រាវជ្រាវនិងស្ថិតិ | សមាជិកអចិន្ត្រៃយ៍ |

៦. ប្រធាននាយកដ្ឋានគ្រប់គ្រងការប្តូរប្រាក់ សមាជិក
៧. ប្រធាននាយកដ្ឋានត្រួតពិនិត្យ សមាជិក
៨. ប្រធាននាយកដ្ឋានប្រតិបត្តិការ សមាជិក
៩. ប្រធាននាយកដ្ឋានបោះផ្សាយ និងឃ្លាំងបេឡា សមាជិក

**ប្រការពីរថ្មី.-**

គណៈកម្មការថ្មី រួមមានសមាសភាព ៖

| | | |
|---|---|---|
| ១. ឯកឧត្តម ជា ចាន់តូ | ទេសាភិបាល | ប្រធាន |
| ២. ឯកឧត្តម ស៊ុំ សន្និសិទ្ធ | អគ្គលេខាធិការ | អនុប្រធាន |
| ៣. ឯកឧត្តម ប៉ាល់ ប៊ុយបុណ្ណាង | អគ្គនាយកត្រួតពិនិត្យ | សមាជិក |
| ៤. លោកស្រី ងួន សុខា | អគ្គនាយកបច្ចេកទេស | សមាជិក |
| ៥. លោកស្រី អ៊ុច សុខុម | ប្រធាននាយកដ្ឋានបេឡា | សមាជិក |
| ៦. លោកស្រី សាយ សំអាត | ប្រធាននាយកដ្ឋានគ្រប់គ្រងការប្តូរប្រាក់ | សមាជិក |
| ៧. លោក ថៃ សភា | ប្រធាននាយកដ្ឋានស្រាវជ្រាវសេដ្ឋកិច្ច និងសហប្រតិបត្តិការអន្តរជាតិ | សមាជិកអចិន្ត្រៃយ៍ ។ |

**ប្រការ ៣.-**

សមាជិកគណៈកម្មការត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ឬអនុប្រធាន ក្នុងករណីអវត្តមានរបស់ប្រធាន និងអាចអញ្ជើញមន្ត្រីជំនាញផ្សេងទៀតឲ្យចូលរួមក្នុងការប្រជុំតាមការចាំបាច់។

**ប្រការ ៤.-**

ការប្រជុំរបស់គណៈកម្មការត្រូវធ្វើយ៉ាងហោចណាស់រៀងរាល់ពីរខែម្តង ។ ក្នុងករណីមានតម្រូវការចាំបាច់ប្រធានគណៈកម្មការអាចកោះប្រជុំគណៈកម្មការនៅពេលណាក៏បាន ។

**ប្រការ ៥.-**

គណៈកម្មការមានមុខងារ និងភារកិច្ចដូចខាងក្រោម:

- កំណត់ ដឹកនាំ និង អនុវត្តគោលនយោបាយរូបិយវត្ថុ សំដៅរក្សាស្ថិរភាពថ្លៃ ដើម្បីទ្រទ្រង់ដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ច នៅក្នុងក្របខ័ណ្ឌនៃគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុរបស់រាជរដ្ឋាភិបាល
- ដាក់នូវវិធានការចាំបាច់ សំដៅធ្វើឲ្យស្ថានភាពសាច់ប្រាក់ងាយស្រួលក្នុងទីផ្សាររូបិយវត្ថុ ស្របតាមគោលដៅនៃការរក្សាស្ថិរភាពថ្លៃ
- សម្របសម្រួលទៅតាមលទ្ធភាព ជាមួយមាសធាតុផ្សេងៗនៃក្របខ័ណ្ឌគោលនយោបាយសេដ្ឋកិច្ច ពិសេសគោលនយោបាយសារពើពន្ធ សំដៅទ្រទ្រង់ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច។
- សម្របសម្រួលទំនាក់ទំនងរវាងគោលនយោបាយរូបិយវត្ថុ និងបទបញ្ញត្តិប្រុងប្រយ័ត្ននៃការត្រួតពិនិត្យធនាគារ
- ផ្សព្វផ្សាយគោលនយោបាយរូបិយវត្ថុ និងការអនុវត្តគោនយោបាយរូបិយវត្ថុ ។

**ប្រការ ៦.-**

នាយកដ្ឋានស្រាវជ្រាវសេដ្ឋកិច្ច និងសហប្រតិបត្តិការអន្តរជាតិ ជាលេខាធិការដ្ឋានអចិន្ត្រៃយ៍របស់គណៈកម្មការនេះ ។ លេខាធិការដ្ឋានអចិន្ត្រៃយ៍របស់គណៈកម្មការមានក្រុមជំនួយការមកពីនាយកដ្ឋាន និងអង្គភាពពាក់ព័ន្ធនៅក្រោមឱវាទរបស់ធនាគារជាតិនៃកម្ពុជា ។ ក្រុមការងារនេះត្រូវស្ថិតក្រោមការគ្រប់គ្រងទទួលខុសត្រូវរបស់ប្រធាននាយកដ្ឋានស្រាវជ្រាវសេដ្ឋកិច្ច និងសហប្រតិបត្តិការអន្តរជាតិ ។ សមាសភាពក្រុមការងារត្រូវតែងតាំតាមសេចក្តីបង្គាប់ការរបស់ទេសាភិបាល និងមានមុខងារ ភារកិច្ចដូចខាងក្រោម :

១. រៀបចំ និងផ្តល់ជូនគណៈកម្មការនូវព័ត៌មាន ព្រមទាំងទិន្នន័យពាក់ព័ន្ធនឹងស្ថានភាព និងនិន្នាការសេដ្ឋកិច្ច ដើម្បីបម្រើដល់ការសម្រេចចិត្តរបស់គណៈកម្មការក្នុងការកំណត់គោលដៅ យុទ្ធសាស្ត្រ វិធានការ ឬឧបករណ៍គោលនយោបាយរូបិយវត្ថុ

២. រៀបចំរបាយការណ៍អំពីលទ្ធផលនៃការប្រជុំរបស់គណៈកម្មការ ។

**ប្រការ ៧.-**

កំណត់ហេតុអង្គប្រជុំគណៈកម្មការត្រូវរៀបចំឲ្យរួចស្រេចយ៉ាងយូរមួយសប្តាហ៍ក្រោយពេលប្រជុំ ។

**ប្រការ ៨.-**

អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋានបច្ចេកទេស អគ្គនាយកដ្ឋានត្រួតពិនិត្យ អគ្គបេឡា អគ្គាធិការដ្ឋាន គ្រប់នាយកដ្ឋាន អង្គភាពក្រោមឱវាទធនាគារជាតិនៃកម្ពុជា ព្រមទាំងសាមីជននៅក្នុងប្រការ២ ត្រូវអនុវត្តប្រកាសនេះឲ្យមានប្រសិទ្ធភាពតាមភារកិច្ចរៀងៗខ្លួន ។

**ប្រការ ៩.**

ប្រកាសនេះមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១១

**ទេសាភិបាល**

**ជា ចាន់តូ**

<u>កន្លែងទទួល</u> :
- ដូចប្រការ ១ និង ប្រការ៨ "ដើម្បីអនុវត្ត"
- កាលប្បវត្តិ
- ឯកសារ

**ចម្លងជូន** :
- គ្រប់សមាជិកក្រុមប្រឹក្សាភិបាល
- ទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីជ្រាបជាព័ត៌មាន"
- នាយកដ្ឋានរដ្ឋបាលទីស្តីការគណៈរដ្ឋមន្ត្រី

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ធ១-០១១-១១១ ប្រ.ក

# ប្រកាស
## ស្ដីពី
## ការបង្កើតគណៈកម្មការស្ថិរភាពហិរញ្ញវត្ថុ

**ទេសាភិបាលធនាគារជាតិនៃកម្ពុជា**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី ២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៦ ចុះថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីវិសោធនកម្មមាត្រា ១៤ និងមាត្រា ៥៧ នៃច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០៨/៥២៦ ចុះថ្ងៃទី ១៣ ខែឧសភា ឆ្នាំ២០០៨ ស្ដីពីការតែងតាំងឯកឧត្ដម **ជា ចាន់តូ** ជាអគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា មានឋានៈស្មើទេសរដ្ឋមន្ត្រី
- យោងតាមប្រកាសលេខ ធ៩៨-៣៨៥ ប្រ.ក ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៨ ស្ដីពីរចនាសម្ព័ន្ធរបស់ធនាគារជាតិនៃកម្ពុជា និងមុខងារ-ភារកិច្ចរបស់បណ្ដាអង្គភាពក្រោមឱវាទ
- យោងតាមប្រកាសលេខ ធ១-០១០-១៩៤ ប្រ.ក ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១០ ស្ដីពីការកែសម្រួលប្រការ៣ ប្រការ៤ ប្រការ៥ ប្រការ១២ និងប្រការ១៣ នៃប្រកាសស្ដីពីរចនាសម្ព័ន្ធរបស់ធនាគារជាតិនៃកម្ពុជា និងមុខងារភារកិច្ចរបស់បណ្ដាអង្គភាពក្រោមឱវាទ
- យោងតាមសំណើររបស់អគ្គនាយកដ្ឋានបច្ចេកទេស

## សម្រេច

**ប្រការ ១.-**

បង្កើតគណៈកម្មការស្ថិរភាពហិរញ្ញវត្ថុ ដែលមានសមាសភាពដូចខាងក្រោម ៖

| | | |
|---|---|---|
| ១. លោកជំទាវ នាវ ច័ន្ទថាណា | ទេសាភិបាលរង | ប្រធាន |
| ២. ឯកឧត្ដម ប៉ាល់ ប៊ុយបុណ្ណាង | អគ្គនាយកត្រួតពិនិត្យ | អនុប្រធាន |
| ៣. លោកស្រី ងួន សុខា | អគ្គនាយកបច្ចេកទេស | សមាជិក |
| ៤. លោកស្រី ជា សិរី | អគ្គនាយករងត្រួតពិនិត្យ | សមាជិក |
| ៥. លោក តាន់ សុខាន់ | ប្រធាននាយកដ្ឋានស្ថិតិ | សមាជិក |
| ៦. លោក យូ វុណ្ណី | អនុប្រធាននាយកដ្ឋានស្រាវជ្រាវសេដ្ឋកិច្ច និងសហប្រតិបត្តិការអន្តរជាតិ | សមាជិកអចិន្ត្រៃយ៍ |

/-

៧. លោក ង៉េត សុវណ្ណារិទ្ធ នាយករងនៃមណ្ឌលសិក្សា
បច្ចេកទេសធនាគារ សមាជិក ។

**ប្រការ ២.-**

សមាជិកគណៈកម្មការត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ឬអនុប្រធាន ក្នុងករណីអវត្តមានរបស់ប្រធាន និងអាចអញ្ជើញមន្ត្រីជំនាញផ្សេងទៀតឲ្យចូលរួមក្នុងការប្រជុំតាមការចាំបាច់។

**ប្រការ ៣.-**

ការប្រជុំរបស់គណៈកម្មការត្រូវធ្វើយ៉ាងហោចណាស់រៀងរាល់ពីរខែម្តង។ ក្នុងករណីមានតម្រូវការចាំបាច់ ប្រធានគណៈកម្មការអាចកោះប្រជុំគណៈកម្មការនៅពេលណាក៏បាន ។

**ប្រការ ៤.-**

គណៈកម្មការមានមុខងារ និងភារកិច្ចដូចខាងក្រោមៈ

- កំណត់ ដឹកនាំ និងអនុវត្តគោលនយោបាយ សំដៅរក្សាស្ថិរភាពហិរញ្ញវត្ថុ ដើម្បីទ្រទ្រង់ការអភិវឌ្ឍន៍សេដ្ឋកិច្ចប្រកបដោយចីរភាព
- ដាក់នូវវិធានការចាំបាច់នានា ដើម្បីគាំទ្របេសកម្មរបស់ធនាគារជាតិនៃកម្ពុជា ក្នុងការគ្រប់គ្រងសាច់ងាយស្រួល និងហានិភ័យនានាក្នុងវិស័យហិរញ្ញវត្ថុ
- ត្រួតពិនិត្យមើលពីអន្តរកម្មរវាងភ្នាក់ងារផ្សេងៗរបស់ទីផ្សារហិរញ្ញវត្ថុ គោលដៅរបស់នយោបាយរូបិយវត្ថុ និងឥទ្ធិពលមកលើប្រព័ន្ធធនាគារ និងវិភាគពីហានិភ័យដែលអាចកើតឡើង និង
- វិភាគ និងតាមដានស្ថិរភាពហិរញ្ញវត្ថុ ។

**ប្រការ ៥.-**

នាយកដ្ឋានស្រាវជ្រាវសេដ្ឋកិច្ច និងសហប្រតិបត្តិការអន្តរជាតិ ជាលេខាធិការដ្ឋានអចិន្ត្រៃយ៍របស់គណៈកម្មការនេះ ។ លេខាធិការដ្ឋានអចិន្ត្រៃយ៍របស់គណៈកម្មការមានក្រុមជំនួយការមកពីនាយកដ្ឋាន និងអង្គភាពពាក់ព័ន្ធនៅក្រោមឱវាទរបស់ធនាគារជាតិនៃកម្ពុជា ។ ក្រុមការងារនេះត្រូវស្ថិតក្រោមការគ្រប់គ្រងទទួលខុសត្រូវរបស់ប្រធាននាយកដ្ឋានស្រាវជ្រាវសេដ្ឋកិច្ច និងសហប្រតិបត្តិការអន្តរជាតិ ។ សមាសភាពក្រុមការងារត្រូវតែងតាំតាមសេចក្តីបង្គាប់ការរបស់ទេសាភិបាល និងមានមុខងារ ភារកិច្ចដូចខាងក្រោម :

- រៀបចំ និងផ្តល់ជូនគណៈកម្មការនូវព័ត៌មាន ព្រមទាំងទិន្នន័យពាក់ព័ន្ធនឹងស្ថានភាព និងនិន្នាការសេដ្ឋកិច្ច ដើម្បីបម្រើដល់ការសម្រេចចិត្តរបស់គណៈកម្មការក្នុងការកំណត់គោលដៅ យុទ្ធសាស្ត្រ និងវិធានការនានា
- សិក្សាពីស្ថិរភាពហិរញ្ញវត្ថុ និងធាតុផ្សេងៗ ដែលអាចមានឥទ្ធិពល និងអាចបណ្តាលឲ្យមានអស្ថិរភាពហិរញ្ញវត្ថុ
- រៀបចំរបាយការណ៍អំពីលទ្ធផលនៃការប្រជុំរបស់គណៈកម្មការ ។

**ប្រការ ៦.-**

កំណត់ហេតុអង្គប្រជុំគណៈកម្មការត្រូវរៀបចំឲ្យរួចស្រេចយ៉ាងយូរមួយសប្តាហ៍ក្រោយពេលប្រជុំ ។

**ប្រការ ៧.-**

អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋានបច្ចេកទេស អគ្គនាយកដ្ឋានត្រួតពិនិត្យ អគ្គបេឡា អគ្គាធិការដ្ឋាន គ្រប់នាយកដ្ឋាន អង្គភាពក្រោមឱវាទធនាគារជាតិនៃកម្ពុជា ព្រមទាំងសាមីជននៅក្នុងប្រការ២ ត្រូវអនុវត្ត ប្រកាសនេះឲ្យមានប្រសិទ្ធភាពតាមភារកិច្ចរៀងៗខ្លួន ។

**ប្រការ ៨.-**

ប្រកាសនេះមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១១

**ទេសាភិបាល**

**ជា-ចាន់តូ**

<u>កន្លែងទទួល</u> :

- ដូចប្រការ ១ និងប្រការ ៧

"ដើម្បីអនុវត្ត"

- កាលប្បវត្តិ
- ឯកសារ

<u>ចម្លងជូន</u> :

- គ្រប់សមាជិកក្រុមប្រឹក្សាភិបាល
- ទីស្តីការគណៈរដ្ឋមន្ត្រី

"ដើម្បីជ្រាបជាព័ត៌មាន"

- នាយកដ្ឋានរដ្ឋបាលទីស្តីការគណៈរដ្ឋមន្ត្រី ✓

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
លេខ : ២៤២ ឧ.ក.រ.ក.ឋ.ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី ០៤ ខែ មេសា ឆ្នាំ២០១១

# ប្រកាស
## ស្តីពី
## នីតិវិធីអនុវត្តបទប្បញ្ញត្តិ លើកិច្ចដំណើរការរោងចក្រ និងសិប្បកម្ម

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ស្តីពីការប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និង សិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- បានឃើញប្រកាសលេខ ៦០៧ ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០០៩ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ស្តីពីនីតិវិធី និងបែបបទស្នើសុំបង្កើតរោងចក្រ និងសិប្បកម្ម
- យោងតាមសំណូមពរចាំបាច់របស់ក្រសួង

# សម្រេច

## ផ្នែកទី១

## បទប្បញ្ញត្តទូទៅ

## គោលដៅ គោលបំណង និង និយមន័យ

### ប្រការ ១ : គោលដៅ

ប្រកាសស្តីពី នីតិវិធីអនុវត្តបទប្បញ្ញត្តិលើកិច្ចដំណើរការរោងចក្រ និងសិប្បកម្ម ហៅកាត់ថា "ប្រកាស" ត្រូវបានដាក់ចេញឱ្យអនុវត្តដោយយោងតាមច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ដែលប្រកាសឱ្យប្រើដោយ ព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ហៅកាត់ថា "ច្បាប់" ក្នុងគោលដៅដូចខាងក្រោមៈ

- ជំរុញការអភិវឌ្ឍន៍ និង កិច្ចដំណើរការរោងចក្រនិងសិប្បកម្ម ឱ្យអនុលោមតាមច្បាប់ ដើម្បីជានាការពារសុខុមាលភាពសាធារណៈ បរិស្ថាន និងសង្គម ។
- ជំរុញតម្លាភាព ក្នុងការអនុវត្តន៍បទប្បញ្ញត្តិលើកិច្ចដំណើរការរោងចក្រ និងសិប្បកម្ម ។

### ប្រការ ២ : គោលបំណង

ប្រកាសនេះកំណត់អំពីៈ

-នីតិវិធីអនុវត្តបទប្បញ្ញត្តិនានា ដែលកំណត់ដោយច្បាប់ពាក់ព័ន្ធនិងការប្រព្រឹត្តទៅនៃកិច្ចដំណើរការរោងចក្រ និងសិប្បកម្ម ។

- បែបបទ និង កាតព្វកិច្ច ដែលត្រូវបំពេញដោយម្ចាស់រោងចក្រនិងសិប្បកម្ម ក្នុងការទទួលបាន និង ពន្យារបន្តវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រនិងសិប្បកម្ម ។

- វិធាន និង នីតិវិធី ក្នុងការចេញបទប្បញ្ញត្តិបច្ចេកទេសផ្សេងៗទៀត ដោយក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

### ប្រការ ៣ : និយមន័យ

**ប្រកាសអនុញ្ញាតបង្កើតរោងចក្រនិងសិប្បកម្មៈ** គឺជាការអនុញ្ញាតជាលាយលក្ខណ៍អក្សរ មានសុពលភាពអចិន្ត្រៃយ៍ ដែលចេញដោយក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល សម្រាប់ការបង្កើតរោងចក្រថ្មី ឬសិប្បកម្មថ្មី ដែលតម្រូវឲ្យសុំច្បាប់ រួមទាំងលក្ខខណ្ឌលម្អិតនានា ដែលចែងក្នុងប្រកាសអនុញ្ញាតនោះ ។ ក្រោយពេលបញ្ចប់ការសាងសង់រួចរាល់ រោងចក្រនិងសិប្បកម្ម ត្រូវមានវិញ្ញាបនបត្រអនុញ្ញាតដំណើរការមួយទៀត មុននឹងចាប់ផ្តើមប្រតិបត្តិការដំបូង ។

**រោងចក្រៈ** គឺសហគ្រាសកម្មន្តសាលដែលមាន ឬរំពឹងថានឹងមាន ឧបករណ៍ ម៉ាស៊ីន សម្ភារៈ និងបរិក្ខារ ដែលត្រូវប្រើនៅក្នុងសហគ្រាសដើម្បីផលិតផលិតផល ដែលមានទុនសមមូលសរុបស្មើ ឬច្រើនជាង ៥០.០០០ (ហាសិបពាន់) ដុល្លារ អាមេរិក ។

**សិប្បកម្មៈ** គឺជាសហគ្រាសកម្មន្តសាលដែលមាន ឬរំពឹងថានឹងមាន ឧបករណ៍ ម៉ាស៊ីន សម្ភារៈនិងបរិក្ខារ ដែលត្រូវប្រើនៅក្នុងរោងចក្រនិងសិប្បកម្ម ដើម្បីផលិតផលិតផលដែលមានទុនសមមូលសរុបតិចជាង ៥០.០០០ (ហាសិបពាន់) ដុល្លារអាមេរិក ។

ក

**សិប្បកម្មតម្រូវឱ្យសុំប្រកាសអនុញ្ញាតបង្កើត:** ដើម្បីការពារសុខភាពសាធារណៈ ប្រភេទសិប្បកម្មមួយចំនួន ដែលផលិតម្ហូបអាហារ ឬភេសជ្ជៈសម្រាប់មនុស្សទទួលទាន ផលិតសារធាតុគីមី ឬផលិតសារធាតុមានគ្រោះថ្នាក់ផ្សេងទៀត ត្រូវធ្វើការស្នើសុំប្រកាសអនុញ្ញាតបង្កើត និង វិញ្ញាបនបត្រអនុញ្ញាតដំណើរការជាមុន ពី ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល មុននឹងបង្កើត ឬចាប់ផ្តើមដំណើរការ ។

**សិប្បកម្មតម្រូវស្នើសុំចុះបញ្ជី:** សិប្បកម្មទាំងអស់ដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ និងប្រកាសនេះ ក្រៅពីប្រភេទសិប្បកម្មតម្រូវលើកលែង និងសិប្បកម្មតម្រូវសុំប្រកាសអនុញ្ញាតបង្កើត ត្រូវធ្វើការស្នើសុំចុះបញ្ជីត្រឹមត្រូវនៅមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល រាជធានី ខេត្ត ។

**សិប្បកម្មតម្រូវលើកលែង:** គឺជាសិប្បកម្មដែលមាន ឬរំពឹងថាមានឧបករណ៍ ម៉ាស៊ីន សម្ភារៈ និង បរិក្ខារដែលត្រូវប្រើនៅក្នុងសិប្បកម្ម សម្រាប់ផលិតដែលមានទុនសមមូលសរុបតិចជាង ៣.០០០ (បីពាន់) ដុល្លារអាមេរិក និងមិនផលិតនូវផលិតផលណាដែលមាននៅក្នុងបញ្ជីរោងចក្រនិងសិប្បកម្ម តម្រូវឱ្យសុំប្រកាសអនុញ្ញាតបង្កើត ។

**ម្ចាស់រោងចក្រ និងសិប្បកម្ម:** គឺជារូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានសិទ្ធិប្រើប្រាស់រោងចក្រនិងសិប្បកម្ម ទទួលផលពីការគ្រប់គ្រងរោងចក្រនិងសិប្បកម្មដែលជាទ្រព្យសម្បត្តិរបស់ខ្លួន និងមានការទទួលស្គាល់ ពី ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

**អ្នកគ្រប់គ្រង:** គឺជាបុគ្គលដែលបានទទួលការតែងតាំងពីម្ចាស់រោងចក្រ និងសិប្បកម្ម ឱ្យទទួលខុសត្រូវលើកិច្ចដំណើរការរោងចក្រ និងសិប្បកម្ម និងភាពអនុលោមតាមច្បាប់ ។

**ភាពមិនអនុលោមតាមច្បាប់:** គឺជាការពិនិត្យឃើញរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ឬដោយមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល ភាពមិនអនុលោមតាមលក្ខខណ្ឌតម្រូវមួយ ឬច្រើនរបស់ច្បាប់ ប្រកាស បទបញ្ញាបច្ចេកទេស ឬវិធានផ្សេងៗទៀត ។

**ពាក្យសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការដំបូង:** គឺជាសេចក្តីប្រកាសជាលាយលក្ខណ៍អក្សរពីអ្នកស្នើសុំបញ្ជាក់ថា រោងចក្រនិងសិប្បកម្មរបស់ខ្លួន ដែលមានប្រកាសអនុញ្ញាតបង្កើតរោងចក្រនិងសិប្បកម្មនោះ ត្រូវបានសាងសង់រួចរាល់និងមានលក្ខណៈគ្រប់គ្រាន់ អាចចាប់ផ្តើមដំណើរការដោយអនុលោមតាមបទដ្ឋានបច្ចេកទេសនិងស្តង់ដារ ដែលកំណត់ដោយក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ស្របតាមលក្ខខណ្ឌនៃប្រកាសអនុញ្ញាតបង្កើត។ ចំពោះសិប្បកម្ម ដែលតម្រូវឱ្យស្នើសុំចុះបញ្ជីពាក្យស្នើសុំចុះបញ្ជី គឺជាពាក្យស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការជាមួយគ្នា ដោយពុំចាំបាច់មានការធ្វើពាក្យស្នើសុំដោយឡែកបន្ថែមទៀតទេ ។

**វិញ្ញាបនបត្រអនុញ្ញាតដំណើរការ:** គឺជាការទទួលស្គាល់ជាលាយលក្ខអក្សរ ពី មន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល បញ្ជាក់ថា សិប្បកម្ម ដែលតម្រូវស្នើសុំចុះបញ្ជី បានចុះបញ្ជីត្រឹមត្រូវ ឬ ពី ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ថារោងចក្រនិងសិប្បកម្មដែលតម្រូវឱ្យសុំប្រកាសអនុញ្ញាតបង្កើត ត្រូវបានសាងសង់រួចរាល់ស្របតាមបទប្បញ្ញត្តិ ដែលមានចែងក្នុងប្រកាសអនុញ្ញាតបង្កើតរោងចក្រនិងសិប្បកម្ម ឬបទដ្ឋានបច្ចេកទេសផ្សេងៗទៀត ដែលកំពុងមានជាធរមាន របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ហើយម្ចាស់រោងចក្រនិងសិប្បកម្ម អាចចាប់ផ្តើមធ្វើការផលិត ឬ ដំណើរការរោងចក្រនិងសិប្បកម្មរបស់ខ្លួន ដោយស្របច្បាប់ ។

**លេខសំគាល់អត្តសញ្ញាណ:** រោងចក្រនិងសិប្បកម្មទាំងអស់ ដែលទទួលបានវិញ្ញាបនបត្រអនុញ្ញាតដំណើរការដំបូង របស់ខ្លួន ស្របតាមប្រកាសនេះនឹងត្រូវទទួលបាន ក្នុងពេលជាមួយគ្នានោះនូវលេខសំគាល់អត្តសញ្ញាណតែមួយគត់ សម្រាប់រោងចក្រ និងសិប្បកម្ម ដើម្បីប្រើជាអត្តសញ្ញាណយោង ងាយស្រួលក្នុងការគ្រប់គ្រងទិន្នន័យ និងស្ថិតិ ។

**បទបញ្ជាបច្ចេកទេស:** គឺជាឯកសារដែលផ្តល់ការណែនាំពិស្តារលើការអនុវត្តន៍ច្បាប់ ប្រកាស និងបទដ្ឋានបច្ចេកទេស ដើម្បីធានាសុវត្ថិភាពមនុស្ស ទ្រព្យសម្បត្តិ បរិស្ថាន នៅក្នុង ឬក្រៅរោងចក្រនិងសិប្បកម្ម ។

បទបញ្ជាបច្ចេកទេសមាន:

១. បទបញ្ជា ស្តីពី នីតិវិធីរដ្ឋបាល

២. បទបញ្ជា ស្តីពី របបរាយការណ៍

៣. បទបញ្ជាបច្ចេកទេស ស្តីពី កិច្ចដំណើរការរោងចក្រនិងសិប្បកម្ម

៤. បទបញ្ជាបច្ចេកទេស ស្តីពី វត្ថុធាតុដើម

៥. បទបញ្ជាបច្ចេកទេស ស្តីពី ផលិតផល

**បទបញ្ជាអន្តរកាល:** គឺជាបទបញ្ជាដែលក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល បញ្ជាទៅម្ចាស់ ឬអ្នកគ្រប់គ្រងរោងចក្រនិងសិប្បកម្ម ទាំងអស់ដែលបានបង្កើត ឬ/និងបានដំណើរការ ហើយមិនទាន់មានវិញ្ញាបនបត្រអនុញ្ញាតដំណើរការ ឱ្យមកបំពេញសំណុំបែបបទស្នើសុំ ដើម្បីទទួលបានវិញ្ញាបនបត្រអនុញ្ញាតដំណើរការស្របតាមប្រកាសនេះ ។

**ស្ថានភាពបន្ទាន់:** គឺជាស្ថានភាពដែលមនុស្ស ទ្រព្យសម្បត្តិ ឬ/និងបរិស្ថាន បានទទួលរងគ្រោះថ្នាក់ ឬខូចខាត ឬគំរាមកំហែងធ្ងន់ធ្ងរភ្លាមៗ ដោយសារកិច្ចដំណើរការរោងចក្រនិងសិប្បកម្ម ឬពីផលិតផលដែលបានផលិតរួច ឬពីមធ្យោបាយផលិតកម្មរបស់រោងចក្រនិងសិប្បកម្ម ។ ស្ថានភាពបន្ទាន់រួមបញ្ចូលទាំង អគ្គិភ័យ គ្រោះថ្នាក់ផ្សេងៗ ការលេចធ្លាយសារធាតុគីមី គ្រោះធម្មជាតិ ។ល។

## ជំពូកទី ២
## នីតិវិធីអនុវត្តបញ្ញត្តិកម្ម
## លើកិច្ចដំណើរការរោងចក្រ និងសិប្បកម្ម

### ប្រការ ៤ : ការជំរុញឱ្យមានភាពអនុលោមតាមច្បាប់

ក្នុងគោលបំណងគ្រប់គ្រង និងអនុវត្តបញ្ញត្តិកម្ម លើកិច្ចដំណើរការគ្រប់រោងចក្រនិងសិប្បកម្ម ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល អនុវត្តនូវវិធានការស្របតាមច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រនិងសិប្បកម្ម ដូចតទៅ:

- តម្រូវឱ្យគ្រប់រោងចក្រនិងសិប្បកម្ម ទាំងអស់ ដែលតម្រូវឱ្យសុំប្រកាសអនុញ្ញាត មានប្រកាសអនុញ្ញាតបង្កើតរោងចក្រនិងសិប្បកម្ម និង មានវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រនិងសិប្បកម្ម ត្រឹមត្រូវ ។
- តម្រូវឱ្យគ្រប់សិប្បកម្មទាំងអស់ដែលតម្រូវឱ្យចុះបញ្ជី បានចុះបញ្ជីនៅមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល និងមានវិញ្ញាបនបត្រអនុញ្ញាតដំណើរការសិប្បកម្មត្រឹមត្រូវ ។
- តម្រូវឱ្យគ្រប់រោងចក្រនិងសិប្បកម្មទាំងអស់ មានភាពអនុលោមស្របតាមស្តង់ដារ បទបញ្ជា ឬ សេចក្តីណែនាំបច្ចេកទេសផ្សេងៗ កំណត់ដោយប្រកាសរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។
- ចេញបទបញ្ជាឱ្យរោងចក្រនិងសិប្បកម្ម ធ្វើការកែតម្រូវកំហុស ឬភាពមិនអនុលោមតាមច្បាប់ ឬបទបញ្ជាបច្ចេកទេសផ្សេងៗ ។
- ដាក់ពិន័យចំពោះការប្រព្រឹត្តល្មើស ឬភាពមិនអនុលោមតាមច្បាប់របស់រោងចក្រនិងសិប្បកម្ម ។

- បញ្ឈប់ដំណើរការរោងចក្រនិងសិប្បកម្ម ឬឃាត់ទុកវត្ថុធាតុដើម ឬផលិតផលសម្រេច របស់រោងចក្រ និងសិប្បកម្ម ក្នុងករណីប្រព្រឹត្តល្មើស ។
- ចាត់បញ្ជូនមន្ត្រីមានសមត្ថកិច្ច ចុះធ្វើអធិការកិច្ចលើ កិច្ចដំណើរការរោងចក្រនិងសិប្បកម្ម និងភាពអនុលោមតាមច្បាប់ និងបទបញ្ញាបច្ចេកទេសផ្សេងៗ ដូចបានកំណត់នៅក្នុងផ្នែកទី៣ នៃប្រកាសនេះ។
- ធ្វើពាក្យបណ្តឹងទៅតុលាការ ក្នុងករណីចាំបាច់ផ្សេងៗ ។

**ប្រការ ៥ : ការទទួលបានវិញ្ញាបនបត្រអនុញ្ញាតដំណើរការ**

ដើម្បីបញ្ជាក់នូវភាពអនុលោមតាមច្បាប់ និង បទបញ្ញាបច្ចេកទេសផ្សេងៗ គ្រប់រោងចក្រនិងសិប្បកម្មទាំងអស់ត្រូវមានវិញ្ញាបនបត្រអនុញ្ញាតដំណើរការ ចេញដោយក្រសួង ឬ មន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល ដែលមានសុពលភាពត្រឹមត្រូវ ។ វិញ្ញាបនបត្រអនុញ្ញាតដំណើរការ មានសុពលភាព ៣ (បី) ឆ្នាំ ហើយត្រូវបានបន្តជាស្វ័យប្រវត្តិ ចំពោះរោងចក្រ និង សិប្បកម្ម ណា ដែលបានអនុលោមត្រឹមត្រូវតាមច្បាប់ និងបទបញ្ញាបច្ចេកទេសនានា ដែលបានកំណត់ក្នុងប្រកាសនេះ និង ប្រកាសស្តីពីបទប្បញ្ញត្តិផ្សេងៗទៀត របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល បានធ្វើការបង់កម្រៃសេវាប្បញ្ញត្តិកម្ម ត្រឹមត្រូវទៀងទាត់ និងបានផ្តល់ជូនក្រសួង ឬ មន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល នូវរបាយការណ៍អំពីដំណើរការផលិតកម្មអាជីវកម្មប្រចាំត្រីមាស តាមការកំណត់ ។

វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រនិងសិប្បកម្ម នឹងត្រូវដកហូត ឬព្យួរទុក ក្នុងរយៈពេលបណ្តោះអាសន្ន ណាមួយដោយក្រសួង ឬ មន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងករណីរោងចក្រនិងសិប្បកម្ម ត្រូវបានរកឃើញថាបានប្រព្រឹត្តល្មើស ឬខ្វះភាពអនុលោមធ្ងន់ធ្ងរ តាមច្បាប់ ឬបទបញ្ញាបច្ចេកទេសផ្សេងៗ ។

**ប្រការ ៦ : ការបន្តវិញ្ញាបនបត្រអនុញ្ញាតដំណើរការ**

ក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ មុនកាលបរិច្ឆេទផុតកំណត់សុពលភាពនៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រនិងសិប្បកម្ម ហើយម្ចាស់រោងចក្រនិងសិប្បកម្ម ពុំទាន់ទទួលបានការចេញវិញ្ញាបនបត្របន្តជាស្វ័យប្រវត្តិទេនោះ ម្ចាស់រោងចក្រនិងសិប្បកម្ម ត្រូវធ្វើលិខិតជូនដំណឹងមកអគ្គនាយកដ្ឋានឧស្សាហកម្មនៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ឬមកមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល ដើម្បីស្នើសុំឱ្យចេញវិញ្ញាបនបត្របន្តជាស្វ័យប្រវត្តិ ដោយភ្ជាប់មកជាមួយនូវរបាយការណ៍សង្ខេបលើការបំពេញកាតព្វកិច្ចត្រឹមត្រូវ ស្របតាមការតម្រូវ ដូចមានចែងក្នុងប្រការ៥ ខាងលើ ។

**ប្រការ ៧ : លិខិតបញ្ជា**

លិខិតបញ្ជាគឺជាលិខិតលាយលក្ខអក្សរ បញ្ជាទៅម្ចាស់ ឬអ្នកគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឱ្យធ្វើសកម្មភាពណាមួយ ដើម្បីឱ្យមានភាពអនុលោមតាមច្បាប់ ប្រកាស បទប្បញ្ញត្តិបច្ចេកទេស ឬស្តង់ដារ ដែលកំណត់ដោយក្រសួង ឬមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល ។

ទម្រង់លិខិតបញ្ជាត្រូវបានកំណត់ដោយក្រសួង ឬមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល [illegible] ដូចខាងក្រោមៈ

១- កាលបរិច្ឆេទ

២- ឈ្មោះ អាសយដ្ឋាន និងលេខអត្តសញ្ញាណរោងចក្រនិងសិប្បកម្ម

៣- ឈ្មោះម្ចាស់ ឬអ្នកគ្រប់គ្រងរោងចក្រ និងសិប្បកម្ម

៤- កម្មវត្ថុនៃការមិនអនុលោមតាមច្បាប់ ប្រកាស បទបញ្ញាបច្ចេកទេស ឬស្តង់ដារ
៥- កម្មវត្ថុនៃការកែតម្រូវ
៦- កាលបរិច្ឆេទផុតកំណត់នៃការកែតម្រូវ
៧- ការផាកពិន័យលើកដំបូង
៨- កាលបរិច្ឆេទផុតកំណត់នៃការផាកពិន័យលើកដំបូង
៩- តារាងកំណត់ពេលវេលា និងចំនួនប្រាក់ផាកពិន័យ
១០- ព័ត៌មានអំពីទីកន្លែង និងបែបបទនៃការបង់ប្រាក់ផាកពិន័យ
១១- ទីកន្លែងដែលអាចទំនាក់ទំនងអំពីព័ត៌មានលើការចេញលិខិតបញ្ជា

**ប្រការ ៨ : ការកំណត់រយៈពេលកែតម្រូវ**

ក្រសួង ឬមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល នឹងចេញលិខិតបញ្ជាទៅម្ចាស់ ឬអ្នកគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឲ្យធ្វើការកែតម្រូវជាបន្ទាន់ក្នុងករណីដែលក្រសួង ឬមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល យល់ឃើញថា រោងចក្រ ឬសិប្បកម្មនោះ អាចបង្កហានិភ័យខ្ពស់ដល់សុវត្ថិភាព សុខុមាលភាពសាធារណៈ និងបរិស្ថាន ឬឱ្យធ្វើការកែតម្រូវក្នុងរយៈពេលកំណត់ជាក់លាក់ណាមួយ អាស្រ័យតាមស្ថានភាពជាក់ស្តែង ។

**ប្រការ ៩ : ការផាកពិន័យក្នុងការខកខានធ្វើការកែតម្រូវ**

ក្រសួង ឬមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល នឹងធ្វើការផាកពិន័យចំពោះម្ចាស់ ឬអ្នកគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ដែលខកខាន ឬមិនបានធ្វើការកែតម្រូវទៅតាមលិខិតបញ្ជា។ កំរិតនៃការផាកពិន័យនឹងត្រូវកើនឡើងរហូតដល់អតិបរមា ស្របតាមតារាងកំណត់ពេលវេលា និងចំនួនប្រាក់ផាកពិន័យ ។

**ប្រការ ១០ : ការទទួលខុសត្រូវតាមច្បាប់**

ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នឹងធ្វើពាក្យបណ្តឹងទៅតុលាការ ក្នុងករណីម្ចាស់ ឬអ្នកគ្រប់គ្រងរោងចក្រ និងសិប្បកម្មណាដែលមិនគោរព ឬល្មើសនឹងច្បាប់ធ្ងន់ធ្ងរ ។

**ប្រការ ១១: ការបញ្ឈប់ ឬឃាត់ទុក វត្ថុធាតុដើម ឬផលិតផល**

ក្នុងករណីក្រសួង ឬមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល ពិនិត្យឃើញថាវត្ថុធាតុដើម ដែលមានក្នុងរោងចក្រ និងសិប្បកម្ម ឬផលិតផល ដែលផលិតដោយរោងចក្រនិងសិប្បកម្មណាមួយ បង្កគ្រោះថ្នាក់ដល់មនុស្ស ទ្រព្យសម្បត្តិ និងបរិស្ថាន ក្រសួង ឬមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល អាចៈ

១- បញ្ជាឱ្យម្ចាស់ ឬអ្នកគ្រប់គ្រងរោងចក្រ និងសិប្បកម្ម បញ្ឈប់ការប្រើប្រាស់វត្ថុធាតុដើមនោះ ។
២- បញ្ជាឱ្យម្ចាស់ ឬអ្នកគ្រប់គ្រងរោងចក្រ និងសិប្បកម្ម រក្សាទុកផលិតផលនោះ ក្នុងបរិវេណនៃរោងចក្រ និងសិប្បកម្ម និងមិនអនុញ្ញាតឱ្យយកវាទៅធ្វើ ពាណិជ្ជកម្ម ឬប្រើប្រាស់ឡើយ។
៣- ឃាត់ទុកវត្ថុធាតុដើម និង ផលិតផល រួចដាក់រក្សាទុកក្នុងទីកន្លែងដែលមានសុវត្ថិភាព រង់ចាំការធ្វើអធិការកិច្ចបន្ត ឬធ្វើពាក្យបណ្តឹងទៅតុលាការ ។

**ប្រការ ១២ : ការបញ្ឈប់ ឬឃាត់ទុក ឯកសាររបស់រោងចក្រ និងសិប្បកម្ម**

ក្នុងករណី ដែលក្រសួង ឬមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល ពិនិត្យឃើញថា ឯកសារដែលបានប្រើប្រាស់សំរាប់ណែនាំ ឬបញ្ជាការប្រើប្រាស់វត្ថុធាតុដើម បច្ចេកទេសផលិត ការប្រើប្រាស់គ្រឿងចក្រ គ្រឿងម៉ាស៊ីន ការរក្សាទុកវត្ថុធាតុដើម ឬផលិតផល អាចបណ្តាលឱ្យកើតមានមហន្តរាយដល់មនុស្ស ទ្រព្យសម្បត្តិក្នុងរោងចក្រនិងសិប្បកម្ម ឬទីដីតខាងរោងចក្រ និងសិប្បកម្ម ក្រសួង ឬមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល នឹងធ្វើការបញ្ឈប់ឬឃាត់ទុកឯកសារទាំងនោះ ។

**ប្រការ ១៣ : ការខកខានក្នុងការចុះបញ្ជីសិប្បកម្ម**

គ្រប់សិប្បកម្មតម្រូវស្នើសុំចុះបញ្ជី ត្រូវធ្វើការស្នើសុំចុះបញ្ជីត្រឹមត្រូវនៅមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល រាជធានី ខេត្ត ដែលខ្លួនបោះទីតាំងក្នុងរយៈពេលយ៉ាងយូរ ៧ (ប្រាំពីរ)ថ្ងៃ ក្រោយថ្ងៃដំណើរការ ។ ប្រសិនបើការចុះបញ្ជីធ្វើឡើងមិនបានត្រឹមត្រូវ និងទាន់ពេលកំណត់ មន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល នឹងធ្វើការដាក់ពិន័យស្របតាម មាត្រា៤៣ នៃច្បាប់ ។

**ប្រការ ១៤ : ការបិទរោងចក្រ និងសិប្បកម្ម**

ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល មានសិទ្ធិផ្អាកសកម្មភាព រោងចក្រនិងសិប្បកម្មតម្រូវឱ្យសុំប្រកាសអនុញ្ញាតបង្កើត ទាំងឡាយណា ដែលបានបង្កើតដោយគ្មានប្រកាសអនុញ្ញាតបង្កើតរោងចក្រនិងសិប្បកម្ម ពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ជាបណ្តោះអាសន្ន ក្នុងរយៈពេលណាមួយមានកំណត់ ដើម្បីតម្រូវឱ្យម្ចាស់ ឬអ្នកគ្រប់គ្រងរោងចក្រនិងសិប្បកម្ម ធ្វើការកែតម្រូវកំហុសរបស់ខ្លួនឡើងវិញ ។

ប្រសិនបើការកែតម្រូវធ្វើឡើងបានត្រឹមត្រូវនិងទាន់ពេលកំណត់ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នឹងចេញប្រកាសអនុញ្ញាតបង្កើតរោងចក្រនិងសិប្បកម្ម ។

ប្រសិនបើការកែតម្រូវមិនបានអនុវត្ត ឬអនុវត្តមិនត្រឹមត្រូវ ឬមិនទាន់តាមកាលកំណត់ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល មានសិទ្ធិចេញប្រកាសបិទទ្វាររោងចក្រនិងសិប្បកម្ម ជាស្ថាពរ ។

ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល មានសិទ្ធិចេញបញ្ជាឱ្យម្ចាស់ ឬអ្នកគ្រប់គ្រងរោងចក្រនិងសិប្បកម្ម ផ្អាកដំណើរការរោងចក្រនិងសិប្បកម្ម ទាំងមូល ឬតាមផ្នែកនៃរោងចក្រនិងសិប្បកម្មជាបណ្តោះអាសន្ន ក្នុងរយៈពេលមួយមានកំណត់ ដើម្បីឱ្យម្ចាស់ ឬអ្នកគ្រប់គ្រងរោងចក្រនិងសិប្បកម្ម ធ្វើការកែតម្រូវ ឬកែលម្អឱ្យបានប្រសើរឡើងវិញ ក្នុងករណីៈ

១. មានកំហុសធ្ងន់ធ្ងរផ្នែកបច្ចេកទេស។

២. ដំណើរការរោងចក្រនិងសិប្បកម្ម ខុសពីការអនុញ្ញាតរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល។

៣. ដំណើរការរោងចក្រនិងសិប្បកម្ម អាចបណ្តាលឱ្យមានគ្រោះថ្នាក់ដល់មនុស្ស ឬអន្តរាយដល់ទ្រព្យសម្បត្តិ នៅក្នុង ឬក្រៅរោងចក្រនិងសិប្បកម្ម ។

៤. ម្ចាស់ ឬ អ្នកគ្រប់គ្រងរោងចក្រនិងសិប្បកម្ម មានចេតនាមិនគោរពតាមលិខិតបញ្ជា របស់ ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រសិនបើការកែតម្រូវធ្វើឡើងបានត្រឹមត្រូវ និងទាន់ពេលកំណត់ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ត្រូវចេញបញ្ជាអនុញ្ញាតឱ្យរោងចក្រនិងសិប្បកម្ម បន្តដំណើរការឡើងវិញ ។

ប្រសិនបើការកែតម្រូវមិនបានអនុវត្ត ឬអនុវត្តមិនទាន់កាលកំណត់ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល មានអំណាចចេញប្រកាសបិទទ្វាររោងចក្រ និងសិប្បកម្មជាស្ថាពរ ។

លិខិតបញ្ជាផ្អាកដំណើរការរោងចក្រ និងសិប្បកម្ម ឬប្រកាសបិទទ្វាររោងចក្រ និងសិប្បកម្មជាស្ថាពរ ត្រូវបិទផ្សាយជា សាធារណៈ នៅពីមុខរោងចក្រ និងសិប្បកម្ម ឬចុះផ្សាយតាមសារព័ត៌មាន ។

បទបញ្ជាបិទរោងចក្រ និងសិប្បកម្មបណ្តោះអាសន្ន បានលុបជាស្វ័យប្រវត្តិនូវវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រនិងសិប្បកម្មនោះ ។ មុននឹងចាប់ផ្តើមដំណើរការរោងចក្រនិងសិប្បកម្មជាថ្មី ម្ចាស់រោងចក្រនិងសិប្បកម្ម ត្រូវដាក់ពាក្យសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការថ្មី ។ វិញ្ញាបនបត្រនេះអាចប្រគល់ឱ្យបាន លុះណាតែម្ចាស់រោងចក្រនិងសិប្បកម្ម នោះបានធ្វើការកែតម្រូវ ដូចដែលបានតម្រូវឱ្យធ្វើនៅក្នុងបទបញ្ជាបិទបណ្តោះអាសន្ននោះ ។

ម្ចាស់ ឬអ្នកគ្រប់គ្រងរោងចក្រ និងសិប្បកម្មណាមួយ ដែលបានប្រព្រឹត្តល្មើសហើយត្រូវបានចេញបញ្ជាឱ្យបិទរោងចក្រនិងសិប្បកម្មជាអចិន្ត្រៃយ៍ មិនអាចទទួលបានវិញ្ញាបនបត្រអនុញ្ញាតដំណើរការពីក្រសួង ឬក៏ធ្វើជាអ្នកគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ណាមួយបានឡើយ ក្នុងរយៈពេល ៣ (បី) ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទបិទជាស្ថាពរនោះ ។

## ផ្នែកទី៣
## ឋានានុក្រម និង នីតិវិធីក្នុងការចេញ
## បទបញ្ជាបច្ចេកទេសផ្សេងៗ

### ប្រការ ១៥ : បទបញ្ញាបច្ចេកទេសទូទៅ

ក្នុងគោលបំណង ជំរុញការអភិវឌ្ឍន៍ និងកិច្ចដំណើរការរបស់រោងចក្រ និងសិប្បកម្ម អនុលោមតាមច្បាប់ ដើម្បីធានា ការពារសុខុមាលភាពសាធារណៈ បរិស្ថាន សង្គម និង ជំរុញតម្លាភាព ក្នុងការអនុវត្តន៍បទប្បញ្ញត្តិលើកិច្ចដំណើរការរបស់រោងចក្រ និងសិប្បកម្ម ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ចេញ បទបញ្ជាបច្ចេកទេសផ្សេងៗ ដែលរួមមានៈ

- បទបញ្ជា ស្តីពី នីតិវិធីរដ្ឋបាល
- បទបញ្ជា ស្តីពី របបរាយការណ៍
- បទបញ្ជាបច្ចេកទេស ស្តីពី កិច្ចដំណើរការរោងចក្រ និងសិប្បកម្ម
- បទបញ្ជាបច្ចេកទេស ស្តីពី វត្ថុធាតុដើម
- បទបញ្ជាបច្ចេកទេស ស្តីពី ផលិតផល

**ក- បទបញ្ជា ស្តីពី នីតិវិធីរដ្ឋបាល**

បទបញ្ជា ស្តីពី នីតិវិធីរដ្ឋបាល គឺជាបទបញ្ជាដែលចែងអំពីនីតិវិធីរដ្ឋបាលផ្សេងៗ ដើម្បីគ្រប់គ្រង និងធានាឱ្យមានភាពអនុលោមតាមច្បាប់ ប្រកាស និង បទបញ្ជាបច្ចេកទេសផ្សេងទៀត ។ បទបញ្ជា ស្តីពី នីតិវិធីរដ្ឋបាល មានដូចជាៈ

១- បែបបទនៃការចេញសេចក្តីជូនដំណឹងទៅម្ចាស់រោងចក្រ និងសិប្បកម្ម
២- នីតិវិធីនៃការដាក់ពិន័យ
៣- នីតិវិធី និងវិធាននៃការធ្វើអធិការកិច្ច និង ការធ្វើកំណត់ហេតុអធិការកិច្ច
៤- ក្បួន និងបទដ្ឋាននៃការប្រមូលយកគំរូផលិតផល
៥- បែបបទនៃការទទួល និង ប្រគល់ឱ្យវិញនូវឯកសាររោងចក្រ និងសិប្បកម្ម

៤

៦- នីតិវិធីនៃការបញ្ឈប់ ឬឃាត់ទុកនូវផលិតផល សម្ភារៈវត្ថុធាតុដើម និងឯកសារពាក់ព័ន្ធនានាដែលអាចបណ្តាលឱ្យមានអន្តរាយដល់មនុស្ស ឬដល់ទ្រព្យសម្បត្តិក្នុង រោងចក្រ និងសិប្បកម្ម ឬទីជិតខាងនៃរោងចក្រ និងសិប្បកម្ម

៧- នីតិវិធីនៃការចេញលិខិតបញ្ជា

៨- ការធ្វើពាក្យបណ្តឹងទៅតុលាការ

៩- នីតិវិធីនៃការអនុវត្តន៍បទបញ្ជាបិទរោងចក្រ និងសិប្បកម្មមួយផ្នែក ឬទាំងមូលជាបណ្តោះអាសន្ន ឬជាអចិន្ត្រៃយ៍

១០- ការចេញ និងបន្តវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ និងសិប្បកម្ម

១១- ការធ្វើប្រតិភូកម្មអំណាចពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ទៅមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល ។ល។

**ខ- បទបញ្ជា ស្តីពី របាយការណ៍**

បទបញ្ជា ស្តីពី របាយការណ៍ គឺជាបទបញ្ជាដែលចែងអំពីទម្រង់លិខិត និងនីតិវិធីដែលម្ចាស់ ឬអ្នក គ្រប់គ្រងរោងចក្រនិងសិប្បកម្មទាំងអស់ ទោះជាស្ថិត ឬមិនស្ថិតនៅក្រោមសមត្ថកិច្ចរបស់ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ត្រូវផ្តល់របាយការណ៍ និងទិន្នន័យមកក្រសួង ឬមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល ។

បទបញ្ជា ស្តីពីរបាយការណ៍ មានដូចជា:

១- ទម្រង់របាយការណ៍ និង ទិន្នន័យ

២- ការទទួលខុសត្រូវរបស់ម្ចាស់ ឬអ្នកគ្រប់គ្រងរោងចក្រនិងសិប្បកម្ម លើភាពត្រឹមត្រូវនៃរបាយការណ៍ និង ទិន្នន័យ

៣- ការរក្សាការសម្ងាត់វិជ្ជាជីវៈនៃរបាយការណ៍ និងទិន្នន័យដែលបានផ្តល់

៤- កាលបរិច្ឆេទនៃការផ្តល់របាយការណ៍ និងទិន្នន័យ

៥- ការផាកពិន័យ ចំពោះការមិនផ្តល់ ការខកខាន ការក្លែងបន្លំរបាយការណ៍ និងទិន្នន័យ និងការធ្វើឱ្យលេចធ្លាយរបាយការណ៍ និងទិន្នន័យដោយគ្មានការយល់ព្រមពីម្ចាស់រោងចក្រ និងសិប្បកម្ម ។ល។

**គ. បទបញ្ជាបច្ចេកទេស ស្តីពី កិច្ចដំណើរការរោងចក្រ និងសិប្បកម្ម**

បទបញ្ជាបច្ចេកទេស ស្តីពី កិច្ចដំណើរការរោងចក្រ និងសិប្បកម្ម គឺជាបទបញ្ជា ដែល ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល កំណត់ឱ្យរោងចក្រ និងសិប្បកម្មទាំងអស់ត្រូវអនុវត្ត ដើម្បីធានាបាន លក្ខខណ្ឌសុវត្ថិភាពអប្បបរមាក្នុងកិច្ចដំណើរការរោងចក្រ និងសិប្បកម្ម ។

បទបញ្ជាបច្ចេកទេស ស្តីពី កិច្ចដំណើរការរោងចក្រ និងសិប្បកម្ម មានដូចជា:

១- កិច្ចដំណើរការ និងការថែទាំរោងចក្រ និងសិប្បកម្ម

២- ការការពារអគ្គីភ័យ

៣- ការការពារ ការបំពុលនៅក្នុង និងក្រៅរោងចក្រ និងសិប្បកម្ម ពន្លឺ ខ្យល់ចេញចូល សំលេង រំញ័រ ក្លិន ចំហាយ កំដៅ ផ្សែង ធូលី កាំរស្មី វិទ្យុសកម្ម និងភាពកខ្វក់ផ្សេងទៀត

៤- ស្លាកសញ្ញាសុវត្ថិភាព និងស្លាកសញ្ញាណែនាំការប្រើប្រាស់ម៉ាស៊ីន ។

៥- ស្តង់ដារប្រើប្រាស់ឡចំហាយ ប្រព័ន្ធប្រើប្រាស់ចំហាយ ឧបករណ៍ និងធុងដែលប្រើសម្ពាធខ្ពស់ ។

៦- ការកំណត់ផ្សេងទៀតដែលក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល យល់ឃើញថាចាំបាច់ ។ល។

**ឃ. បទបញ្ជាបច្ចេកទេស ស្តីពី វត្ថុធាតុដើម**

បទបញ្ជាបច្ចេកទេស ស្តីពី វត្ថុធាតុដើម គឺជាបទបញ្ជាដែលក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល កំណត់ឱ្យរោងចក្រ និងសិប្បកម្ម ទាំងអស់ត្រូវអនុវត្ត ដើម្បីធានាបាននូវលក្ខខណ្ឌសុវត្ថិភាពអប្បបរមាក្នុងការដឹកជញ្ជូន រក្សាទុក ប្រើប្រាស់វត្ថុធាតុដើម និងការបញ្ចេញចោលកាកសំណល់ក្នុងកិច្ចដំណើរការរោងចក្រ និងសិប្បកម្ម ។

បទបញ្ជាបច្ចេកទេស ស្តីពី វត្ថុធាតុដើម មានដូចជា:

១- ជាតិផ្ទុះ

២- គ្រឿងឆេះ

៣- ជាតិពុល

៤- ឧស្ម័ន ឬគីមីគ្រោះថ្នាក់

៥- សារធាតុវិទ្យុសកម្ម

៦- កាកសំណល់ឧស្សាហកម្ម

៧- សារធាតុគ្រោះថ្នាក់ ឬបង្កគ្រោះថ្នាក់ផ្សេងទៀត

៨- នីតិវិធីក្នុងការតាមដានម្ចាស់រោងចក្រ និងសិប្បកម្ម ដែលល្មើសនឹងបទបញ្ជាបច្ចេកទេស ស្តីពីវត្ថុធាតុ ។

**ង- បទបញ្ជាបច្ចេកទេស ស្តីពី ផលិតផល**

បទបញ្ជាបច្ចេកទេសស្តីពីផលិតផល គឺជាបទបញ្ជា ដែលក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល កំណត់ឱ្យម្ចាស់រោងចក្រ និងសិប្បកម្ម ទាំងអស់ត្រូវអនុវត្តដើម្បីគ្រប់គ្រងលើ:

១- គុណភាពផលិតផល

២- ស្តង់ដារផលិតផល

៣- ការចុះបញ្ជីផលិតផល និង

៤- ស្លាកបញ្ជាក់ផលិតផល ។ល។

បទបញ្ជាបច្ចេកទេស ស្តីពី ផលិតផល ត្រូវអនុលោមទៅតាមកាតព្វកិច្ចរបស់កម្ពុជា ដែលចែងក្នុងកិច្ចព្រមព្រៀងអង្គការពាណិជ្ជកម្មពិភពលោក រួមមានកិច្ចព្រមព្រៀង ស្តីពីរបាំងបច្ចេកទេស ចំពោះពាណិជ្ជកម្ម និងការអនុវត្តន៍វិធានអនាម័យ និងភូតគាមអនាម័យ ហើយត្រូវផ្អែកលើស្តង់ដារអន្តរជាតិ ដែលទទួលស្គាល់ ដោយអង្គការពាណិជ្ជកម្មពិភពលោក និងអង្គការអន្តរជាតិផ្សេងៗទៀត លើកលែងតែករណីដែលក្រសួង យល់ឃើញថា បទបញ្ជា ឬ ស្តង់ដារបច្ចេកទេសអន្តរជាតិទាំងនោះ មិនសមស្របទៅនឹងតម្រូវការអភិវឌ្ឍន៍សេដ្ឋកិច្ច និងពាណិជ្ជកម្ម របស់កម្ពុជា ។

## ផ្នែកទី៤

## បទប្បញ្ញត្តិផ្សេងៗ

**ប្រការ ១៦ : អ្នកគ្រប់គ្រងរោងចក្រ និងសិប្បកម្ម**

អ្នកគ្រប់គ្រងរោងចក្រ និងសិប្បកម្ម គឺជាបុគ្គលដែលបានទទួលការតែងតាំងពីម្ចាស់រោងចក្រ និងសិប្បកម្ម ឱ្យទទួលខុសត្រូវលើកិច្ចដំណើរការរបស់រោងចក្រ និងសិប្បកម្ម និង ភាពអនុលោមតាមច្បាប់ និងត្រូវជូនដំណឹងជាលាយលក្ខអក្សរមកក្រសួង ឬមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល ។

**ប្រការ ១៧ : ការផ្លាស់ប្តូរម្ចាស់រោងចក្រ និងសិប្បកម្ម**

ក្នុងករណីប្តូរម្ចាស់រោងចក្រ និងសិប្បកម្ម ម្ចាស់រោងចក្រ និងសិប្បកម្មថ្មី ត្រូវធ្វើពាក្យសុំការទទួលស្គាល់ភាពជាម្ចាស់រោងចក្រ និងសិប្បកម្មពីក្រសួង ឬមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល ក្នុងរយៈពេល ១០(ដប់)ថ្ងៃ នៃថ្ងៃធ្វើការយ៉ាងយូរ ចាប់ពីថ្ងៃដែលខ្លួនបានទទួលសិទ្ធិជាម្ចាស់រោងចក្រនិងសិប្បកម្មថ្មី ។ ក្រសួង ឬមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល ត្រូវឆ្លើយតបទៅម្ចាស់រោងចក្រ និងសិប្បកម្មវិញ ក្នុងរយៈពេល ៤ (បួន)ថ្ងៃ នៃថ្ងៃធ្វើការ ចាប់ពីថ្ងៃទទួលពាក្យសុំ ។

**ប្រការ ១៨ : ការដាក់តាំងបង្ហាញវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ និងសិប្បកម្ម និង លិខិត អនុញ្ញាតផ្សេងៗ**

ម្ចាស់រោងចក្រ និងសិប្បកម្មត្រូវតាំងបង្ហាញវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ និងសិប្បកម្ម និង លិខិតអនុញ្ញាតផ្សេងៗ ជាចំហនៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្រ និងសិប្បកម្មរបស់ខ្លួន ។

ក្នុងករណីខកខានមិនបានអនុវត្តម្ចាស់រោងចក្រនិងសិប្បកម្ម នឹងត្រូវទទួលការពិន័យតាមមាត្រា៤៨នៃច្បាប់។

**ប្រការ ១៩ : លិខិតបញ្ជាក់ដែលចេញឱ្យតាមការស្នើសុំរបស់ម្ចាស់រោងចក្រ និងសិប្បកម្ម**

ក្រសួង ឬមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល ត្រូវផ្តល់លិខិតបញ្ជាក់ផ្សេងៗ ពាក់ព័ន្ធនឹងរោងចក្រ និងសិប្បកម្ម តាមការស្នើសុំរបស់ម្ចាស់រោងចក្រ និងសិប្បកម្ម បើពិនិត្យឃើញថាជាការចាំបាច់ ។

**ប្រការ ២០ : វិស្វករ និង អ្នកបច្ចេកទេស**

ក្នុងការបង្កើត និង កិច្ចដំណើរការរោងចក្រ និងសិប្បកម្ម ម្ចាស់រោងចក្រ និងសិប្បកម្មត្រូវប្រើប្រាស់វិស្វករ ឬអ្នកបច្ចេកទេស ដែលមានសញ្ជាតិខ្មែរជាអាទិភាព ។ លក្ខខណ្ឌនៃការប្រើប្រាស់វិស្វករ អ្នកបច្ចេកទេសបរទេស ត្រូវអនុវត្តតាមច្បាប់ដែលមានជាធរមាន ។

**ប្រការ ២១ : ឈ្មោះរោងចក្រ និងសិប្បកម្ម**

រោងចក្រ និងសិប្បកម្មនីមួយៗ ត្រូវមានឈ្មោះ ហើយផ្លាកឈ្មោះត្រូវសរសេរជាអក្សរខ្មែរ មានទំហំធំជាង និងនៅពីលើ អក្សរផ្សេងទៀត ។ ម្ចាស់រោងចក្រ និងសិប្បកម្ម ត្រូវលើកបង្ហាញផ្លាកឈ្មោះរោងចក្រ និងសិប្បកម្មរបស់ខ្លួន នៅកន្លែងដែលងាយមើលឃើញ នៅខាងមុខរោងចក្រ និងសិប្បកម្ម និងនៅលើកញ្ចប់ផលិតផលរបស់ខ្លួន ។

ប្រសិនបើម្ចាស់រោងចក្រ និងសិប្បកម្មចង់ផ្លាស់ប្តូរឈ្មោះរោងចក្រ និងសិប្បកម្ម ម្ចាស់រោងចក្រ និងសិប្បកម្ម នោះ ត្រូវធ្វើសេចក្តីជូនដំណឹងអំពីឈ្មោះថ្មីជាលាយលក្ខអក្សរទៅក្រសួង ឬមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល ឱ្យបាន ១០ (ដប់)ថ្ងៃ មុនថ្ងៃ ប្រើប្រាស់ ។

បន្ទាប់ពីបានជូនដំណឹង ម្ចាស់ ឬអ្នកគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ត្រូវលើកបង្ហាញផ្លាកឈ្មោះថ្មី នៅខាងមុខរោងចក្រ និងសិប្បកម្ម និងលើកញ្ចប់ផលិតផល ។

**ប្រការ ២២ : ការសម្ងាត់នៃរបាយការណ៍រោងចក្រ និងសិប្បកម្ម**

ក្រសួង ឬមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល មិនអាចបោះផ្សាយ ឬចែកចាយរបាយការណ៍ និងទិន្នន័យ របស់រោងចក្រ និងសិប្បកម្មដែលបានផ្តល់ពីម្ចាស់ ឬ អ្នកគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ជាសាធារណៈឡើយ លើកលែងតែមានការអនុញ្ញាតពីម្ចាស់ ឬ អ្នកគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។ ក្រសួង ឬមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពលអាចប្រើប្រាស់របាយការណ៍ និងទិន្នន័យដែលផ្តល់មកនោះ សម្រាប់ធ្វើការវិភាគ និងអាចធ្វើការផ្សព្វផ្សាយការវិភាគនោះ ដោយមិនបញ្ជាក់ពីប្រភពនៃរបាយការណ៍ និង ទិន្នន័យនោះ ។

**ប្រការ ២៣ : ការជូនដំណឹងក្នុងករណីបន្ទាន់**

ក្នុងករណីមានស្ថានភាពបន្ទាន់នៅរោងចក្រ និងសិប្បកម្មណាមួយ ឬ កើតចេញពីផលិតផលនៃរោងចក្រ និងសិប្បកម្មណាមួយ ម្ចាស់ឬអ្នកគ្រប់គ្រងរោងចក្រនិងសិប្បកម្មនោះ ត្រូវផ្តល់សេចក្តីជូនដំណឹងផ្ទាល់មាត់ភ្លាម អំពីស្ថានភាពបន្ទាន់នោះ និងត្រូវផ្តល់សេចក្តីជូនដំណឹងជាលាយលក្ខអក្សរទៅក្រសួង ឬមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងរយៈពេល ៧(ប្រាំពីរ)ថ្ងៃ យ៉ាងយូរ បន្ទាប់ពីការកើតឡើងនៃគ្រោះអាសន្ននោះ ។

## ផ្នែកទី ៥
## អន្តរប្បញ្ញត្តិ និង អវសានប្បញ្ញត្តិ

**ប្រការ ២៤ : បទបញ្ជាអន្តរកាល**

ក្នុងរយៈពេលមួយកំណត់ដោយក្រសួង ឬមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល ម្ចាស់រោងចក្រ និងសិប្បកម្មដែលមិនទាន់មានវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ និងសិប្បកម្ម ត្រូវមកបំពេញបែបបទស្នើសុំ ដើម្បីទទួលបានវិញ្ញាបនបត្រអនុញ្ញាត ដំណើរការរោងចក្រ និងសិប្បកម្ម ស្របតាមប្រកាសនេះ ។

ក្រសួង ឬមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល អាចចេញបទបញ្ជាអន្តរកាលជាដំណាក់កាល និងតាមតំបន់ ។

បទបញ្ជាអន្តរកាលនេះ បញ្ជាក់អំពីៈ

១- គោលបំណង
២- ប្រភេទ ឬ/និងទីតាំងរោងចក្រ និងសិប្បកម្មដែលស្ថិតនៅក្រោមវិសាលភាពនៃបទបញ្ជានេះ
៣- កាលបរិច្ឆេទផុតកំណត់នៃការដាក់ពាក្យសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ និងសិប្បកម្ម
៤- កម្រៃសេវាតម្រូវឱ្យបង់
៥- សំណុំបែបបទ និងឯកសារដែលម្ចាស់រោងចក្រ និងសិប្បកម្មត្រូវបំពេញ
៦- លក្ខខណ្ឌរដ្ឋបាល និងបច្ចេកទេសផ្សេងៗ

ៗ

៧- អាសយដ្ឋាន និងលេខទូរស័ព្ទទំនាក់ទំនង សំរាប់ផ្តល់ព័ត៌មានបន្ថែមដល់ម្ចាស់ ឬអ្នកគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។

**ប្រការ ២៥ : អវសានប្បញ្ញត្ត**

អគ្គនាយកដ្ឋានឧស្សាហកម្ម វិទ្យាស្ថាន នាយកដ្ឋាន អង្គភាពចំណុះអគ្គនាយកដ្ឋានឧស្សាហកម្មអង្គភាពចំណុះក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល និង មន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល រាជធានី ខេត្ត រោងចក្រ និងសិប្បកម្មទាំងអស់ត្រូវអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខា នេះតទៅ ។

ស៊ុយ សែម

ចម្លងជូនៈ

- រាជកិច្ច
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- ក្រសួងព័ត៌មាន
- ក្រសួងបរិស្ថាន
- ក្រសួងយុត្តិធម៌
- គ្រប់សាលារាជធានី-ខេត្ត
- គ្រប់មន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល រាជធានី-ខេត្ត "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខៈ ២៧៥ ប្រក.កសក

ប្រកាស

ស្តីពី

ការបង្កើតស្ថានីយផ្សព្វផ្សាយ និង ស្តារព្រៃឈើបឹងចារ

រដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ព្រៃឈើ
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញអនុក្រឹត្យលេខ ១០៥ អនក្រ.បកចុះថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០០៥ ស្តីពីការបន្ថែមមុខងារ ភារកិច្ចឱ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និង ការបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុង នាយកដ្ឋានផែនការ និង ស្ថិតិ នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និង មជ្ឈមណ្ឌលព័ត៌មាន និង ឯកសារកសិកម្ម ចំណុះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញអនុក្រឹត្យលេខ ១៨៨ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួងទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផលឱ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានកៅ្សត្រសាស្ត្រ និង កែលំអដីកសិកម្មឱ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និង កែសម្រួលអគ្គនាយកដ្ឋានចំការកៅស៊ូ ទៅជាអគ្គនាយកដ្ឋានកៅស៊ូ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

- បានឃើញអនុក្រឹត្យលេខ ៥៣ អនក្រ.បក ចុះថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០០៥ ស្តីពីនីតិវិធីការបង្កើត ការចាត់ថ្នាក់ និង ការចុះបញ្ជិកាសម្បត្តិព្រៃឈើអចិន្ត្រៃយ៍
- បានឃើញអនុក្រឹត្យលេខ ២៦ អនក្រ.បក ចុះថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ២០០៨ ស្តីពីវិធាននៃការផ្តល់សិទ្ធិប្រើប្រាស់ដីព្រៃរបស់រដ្ឋសម្រាប់ការដាំឈើ
- បានឃើញប្រកាសលេខ ៥០៩ ប្រក.កសក.ប ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់រដ្ឋបាលព្រៃឈើ
- បានឃើញប្រកាសលេខ ៣៦១ ប្រក.កសក.ប ចុះថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០១០ ស្តីពីការកែសម្រួលប្រកាសលេខ ៥០៩ ប្រក.កសក.ប ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់រដ្ឋបាលព្រៃឈើ
- តាមសំណើរបស់ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកប្រធានរដ្ឋបាលព្រៃឈើ

## សម្រេច

**ប្រការ ១ :** បង្កើតស្ថានីយផ្សព្វផ្សាយ និង ស្តារព្រៃឈើមួយកន្លែងមានឈ្មោះថា **ស្ថានីយផ្សព្វផ្សាយ និង ស្តារព្រៃឈើបឹងចារ** មានទីតាំងស្ថិតក្នុងដែនដីព្រៃបម្រុងទុកអចិន្ត្រៃយ៍ក្នុងឃុំបឹងចារ និង ឃុំកំពង់ចាម ស្រុកសំបូរ ខេត្តក្រចេះ និង ឃុំសៀមបូក ស្រុកសៀមបូក ខេត្តស្ទឹងត្រែង។

**ប្រការ ២ :** ប្រកាសនេះមានគោលបំណង :

- ស្តារព្រៃឈើឡើងវិញ តាមរយៈការដាំឈើសម្រាប់អភិវឌ្ឍប្រកបដោយនិរន្តរភាពនូវសេដ្ឋកិច្ច សង្គម និង បរិស្ថាន
- អភិវឌ្ឍចំណេះដឹងបច្ចេកទេសដាំឈើ បំផុសការចូលរួមដាំឈើ និង ផ្តល់ការងារធ្វើដល់សហគមន៍មូលដ្ឋាន ដើម្បីបង្កើនជីវភាពរស់នៅរបស់ប្រជាជនក្នុងតំបន់
- ទប់ស្កាត់បង្ក្រាប និង លុបបំបាត់ការកាប់រាន ការដុត ការឈូសឆាយ និង ការហ៊ុមព័ទ្ធកាន់កាប់ដីព្រៃឈើ ដើម្បីធ្វើជាកម្មសិទ្ធិ
- ទប់ស្កាត់ការហូរច្រោះដីជាតិដី និង កែលំអដីតាមរយៈដំណុះព្រៃដាំ និងអភិវឌ្ឍជីវចម្រុះ
- កាត់បន្ថយការប្រើប្រាស់ព្រៃឈើធម្មជាតិ ដោយបង្កើនផលិតផលឈើពីព្រៃដាំ
- ចូលរួមចំណែកក្នុងយន្តការអភិវឌ្ឍស្អាត ឬយន្តការផ្សេងៗទៀតដើម្បីកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់លើភពផែនដី និងទប់ស្កាត់បម្រែបម្រួលអាកាសធាតុ
- ទ្រទ្រង់សកម្មភាពផ្សេងៗ រួមមានការសិក្សាស្រាវជ្រាវវិទ្យាសាស្ត្របច្ចេកទេស ការអប់រំផ្សព្វផ្សាយ បណ្តុះបណ្តាល និង អភិវឌ្ឍសហគមន៍មូលដ្ឋាន។

**ប្រការ ៣ :** ស្ថានីយផ្សព្វផ្សាយ និង ស្តារព្រៃឈើបឹងចារ មានផ្ទៃក្រឡាសរុប ៣៤.០០៧ (សាមសិបបួនពាន់សូន្យរយសូន្យប្រាំពីរ) ហិកតា ដូចមានផែនទីមាត្រដ្ឋាន ១:២០០.០០០ ភ្ជាប់មកជាឧបសម្ព័ន្ធជាប្រព័ន្ធខ្សែព្រំបិទកំណត់ដោយបណ្តាចំណុចនិយាមកា :

A ( 596 257, 1460 004 ), B ( 604 533, 1457 801 ), C ( 608 254, 1454 694 ), D ( 607 387,1450 157 )
E ( 607 485, 1444 738 ), F ( 604 100, 1438 906 ), G ( 605 517, 1432 519 ),H ( 599 409, 1419 242 ),
I ( 599 386, 1422 004), J ( 597 477, 1422 004), K ( 597 477, 1420 998), L (596 195, 1420 998)។

**ប្រការ ៤:** ស្ថានីយផ្សព្វផ្សាយ និង ស្តារព្រៃឈើព្រែកបឹងចារ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់រដ្ឋបាលព្រៃឈើ និងមានភារកិច្ចដូចតទៅ ៖

- ធ្វើការសិក្សាស្រាវជ្រាវបច្ចេកទេសវិទ្យាសាស្ត្រ និង ធ្វើការបណ្តុះកូនឈើ ដាំឈើ ថែរក្សាការពារ និង ប្រមូលផល អនុផលចម្ការព្រៃដាំ
- សហការជាមួយដៃគូអភិវឌ្ឍ ដៃគូវិនិយោគក្នុងប្រទេស ឬ ក្រៅប្រទេសក្នុងការដាំដុះ ផលិត កែច្នៃ និង ប្រមូលផល អនុផលចម្ការព្រៃដាំ
- ជួយបណ្តុះបណ្តាល និង ផ្សព្វផ្សាយបច្ចេកទេសដាំដុះ ផលិត កែច្នៃ និង ផ្តល់មុខរបរដល់សហគមន៍មូលដ្ឋាន
- កៀរគរ ទាក់ទាញ ការចូលរួមគាំទ្រ និង ទទួលជំនួយឧបត្ថម្ភពីគ្រប់មជ្ឈដ្ឋានជាតិ និង អន្តរជាតិ ។

**ប្រការ ៥ :** ដំណើរការ និង ការគ្រប់គ្រងស្ថានីយផ្សព្វផ្សាយ និង ស្តារព្រៃឈើនេះ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធានរដ្ឋបាលព្រៃឈើ ។

**ប្រការ ៦ :** ប្រកាស ឬ សេចក្តីសម្រេចទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ៧ :** អគ្គលេខាធិការ អគ្គាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានផែនការ និងស្ថិតិ ប្រធានរដ្ឋបាលព្រៃឈើ ប្រធានអង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ដែលពាក់ព័ន្ធ និង ប្រធានមន្ទីរកសិកម្មខេត្តក្រចេះ និង ប្រធានមន្ទីរកសិកម្មខេត្តស្ទឹងត្រែង ត្រូវអនុវត្តប្រកាសនេះ តាមភារកិច្ចរៀង១ខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ ៦ ឆ្នាំ ២០១០

រដ្ឋមន្ត្រី

ច័ន្ទ សារុន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ក្រសួងបរិស្ថាន
- សាលាខេត្តក្រចេះ
- សាលាខេត្តស្ទឹងត្រែង
- ដូចប្រការ ៧
- ឯកសារ-កាលប្បវត្តិ

ផែនទី ទីតាំងស្នើសុំបង្កើតស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើ ប៊ឹងចារ ស្ថិតក្នុងស្រុកសំបូរ ខេត្តក្រចេះ និងស្រុកសៀមបូក ខេត្តស្ទឹងត្រែង



ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ: ៦៧៤ ប្រក.កសក

# ប្រកាស

## ស្តីពី

## ការបង្កើតស្ថានីយផ្សព្វផ្សាយ និង ស្តារព្រៃឈើព្រែកប្រសប់

## រដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ព្រៃឈើ
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញអនុក្រឹត្យលេខ ១០៥ អនក្រ.បកចុះថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០០៥ ស្តីពីការបន្ថែមមុខងារ ភារកិច្ចឱ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និង ការបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុង នាយកដ្ឋានផែនការ និង ស្ថិតិ នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និង មជ្ឈមណ្ឌលព័ត៌មាន និង ឯកសារកសិកម្ម ចំណុះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញអនុក្រឹត្យលេខ ១៨៨ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួងទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផលឱ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានក្សេត្រសាស្ត្រ និង កែលំអដីកសិកម្មឱ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និងកែសម្រួលអគ្គនាយកដ្ឋានចំការកៅស៊ូ ទៅជាអគ្គនាយកដ្ឋានកៅស៊ូ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

អាស័យដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា ទូរស័ព្ទលេខ: (០២៣) ៧២៦ ១២៨ ៧២៦ ១២៩ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
No. 200 Preah Norodom Blvd, Sangkat Tonle Basak, Khan Chamkarmon Phnom Penh, Cambodia Phone : (023) 726 128 726 129 Fax : (855) 23 217 320

- បានឃើញអនុក្រឹត្យលេខ ៥៣ អនក្រ.បក ចុះថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០០៥ ស្តីពីនីតិវិធីការបង្កើត ការចាត់ថ្នាក់ និង ការចុះបញ្ជិកាសម្បត្តិព្រៃឈើអចិន្ត្រៃយ៍
- បានឃើញអនុក្រឹត្យលេខ ២៦ អនក្រ.បក ចុះថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ២០០៨ ស្តីពីវិធាននៃការផ្តល់សិទ្ធិប្រើប្រាស់ដីព្រៃរបស់រដ្ឋសម្រាប់ការដាំឈើ
- បានឃើញប្រកាសលេខ ៥០៩ ប្រក.កុសក.បុ ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់រដ្ឋបាលព្រៃឈើ
- បានឃើញប្រកាសលេខ ៣៦១ ប្រក.កសក.បុ ចុះថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០១០ ស្តីពីការកែសម្រួលប្រកាសលេខ ៥០៩ ប្រក.កសក.បុ ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់រដ្ឋបាលព្រៃឈើ
- តាមសំណើរបស់ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកប្រធានរដ្ឋបាលព្រៃឈើ

## សម្រេច

**ប្រការ ១ :** បង្កើតស្ថានីយផ្សព្វផ្សាយ និង ស្តារព្រៃឈើមួយកន្លែងមានឈ្មោះថា **ស្ថានីយផ្សព្វផ្សាយ និង ស្តារព្រៃឈើព្រែកប្រសប់** មានទីតាំងស្ថិតក្នុងដែនដីព្រៃបម្រុងទុកអចិន្ត្រៃយ៍ក្នុងឃុំជ្រោយបន្ទាយ ឃុំសាប និង ឃុំព្រែកប្រសប់ ស្រុកព្រែកប្រសប់ ខេត្តក្រចេះ ។

**ប្រការ ២ :** ប្រកាសនេះមានគោលបំណង :

- ស្តារព្រៃឈើឡើងវិញ តាមរយៈការដាំឈើសម្រាប់អភិវឌ្ឍប្រកបដោយនិរន្តរភាពទូរសេដ្ឋកិច្ច សង្គម និង បរិស្ថាន
- អភិវឌ្ឍចំណេះដឹងបច្ចេកទេសដាំឈើ បំផុសការចូលរួមដាំឈើ និង ផ្តល់ការងារធ្វើដល់សហគមន៍មូលដ្ឋាន ដើម្បីបង្កើនជីវភាពរស់នៅរបស់ប្រជាជនក្នុងតំបន់
- ទប់ស្កាត់បង្ក្រាប និង លុបបំបាត់ការកាប់រាន ការដុត ការឈូសឆាយ និង ការហ៊ុមព័ទ្ធកាន់កាប់ដីព្រៃឈើ ដើម្បីធ្វើជាកម្មសិទ្ធិ
- ទប់ស្កាត់ការហូរច្រោះដីជាតិដី និង កែលំអដីតាមរយៈដំណុះព្រៃដាំ និងអភិវឌ្ឍជីវចម្រុះ
- កាត់បន្ថយការប្រើប្រាស់ព្រៃឈើធម្មជាតិ ដោយបង្កើនផលិតផលឈើពីព្រៃដាំ
- ចូលរួមចំណែកក្នុងយន្តការអភិវឌ្ឍស្អាត ឬយន្តការផ្សេងៗទៀតដើម្បីកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់លើភពផែនដី និងទប់ស្កាត់បម្រែបម្រួលអាកាសធាតុ
- ទ្រទ្រង់សកម្មភាពផ្សេងៗ រួមមានការសិក្សាស្រាវជ្រាវវិទ្យាសាស្ត្របច្ចេកទេស ការអប់រំផ្សព្វផ្សាយ បណ្តុះបណ្តាល និង អភិវឌ្ឍសហគមន៍មូលដ្ឋាន។

**ប្រការ ៣ :** ស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើព្រែកប្រសប់ មានផ្ទៃក្រឡាសរុប ៣០.១៦៤ (សាមសិបពាន់មួយរយហុកសិបបួន) ហិកតា ដូចមានផែនទីមាត្រដ្ឋាន ១:១១០.០០០ ភ្ជាប់មកជាឧបសម្ព័ន្ធជាប្រព័ន្ធខ្សែព្រំបិទកំណត់ដោយបណ្តាចំណុចនិយាមកា:

A ( 595 732, 1401 103 ), B ( 605 206, 1401 206 ),C ( 605 443, 1381 448 ). D (610 264, 1368 961 ),
E ( 605 522, 1367 459 ), F ( 600 780, 1372 122 ), G ( 595 959, 1378 603 ), H ( 594 853, 1381 685 )
I ( 589 399, 1383 977 ), J ( 589 715, 1388 245 ), K ( 595 564, 1389 509 ) ។

**ប្រការ ៤:** ស្ថានីយផ្សព្វផ្សាយ និង ស្ការព្រៃឈើព្រៃកប្រសប់ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់រដ្ឋបាលព្រៃឈើ និងមានភារកិច្ចដូចតទៅ ៖

- ធ្វើការសិក្សាស្រាវជ្រាវបច្ចេកទេសវិទ្យាសាស្ត្រ និង ធ្វើការបណ្តុះកូនឈើ ដាំឈើ ថែរក្សាការពារ និង ប្រមូលផល អនុផលចម្ការព្រៃដាំ
- សហការជាមួយដៃគូអភិវឌ្ឍ ដៃគូវិនិយោគក្នុងប្រទេស ឬ ក្រៅប្រទេសក្នុងការដាំដុះ ផលិត កែច្នៃ និង ប្រមូលផល អនុផលចម្ការព្រៃដាំ
- ជួយបណ្តុះបណ្តាល និង ផ្សព្វផ្សាយបច្ចេកទេសដាំដុះ ផលិត កែច្នៃ និង ផ្តល់មុខរបរដល់សហគមន៍មូលដ្ឋាន
- កៀរគរ ទាក់ទាញ ការចូលរួមគាំទ្រ និង ទទួលជំនួយឧបត្ថម្ភពីគ្រប់មជ្ឈដ្ឋានជាតិ និង អន្តរជាតិ ។

**ប្រការ ៥ :** ដំណើរការ និង ការគ្រប់គ្រងស្ថានីយផ្សព្វផ្សាយ និងស្ការព្រៃឈើនេះ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធានរដ្ឋបាលព្រៃឈើ ។

**ប្រការ ៦ :** ប្រកាស ឬ សេចក្តីសម្រេចទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ៧ :** អគ្គលេខាធិការ អគ្គាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានផែនការ និងស្ថិតិ ប្រធានរដ្ឋបាលព្រៃឈើ ប្រធានអង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ដែលពាក់ព័ន្ធ និង ប្រធានមន្ទីរកសិកម្មខេត្តក្រចេះ ត្រូវអនុវត្តប្រកាសនេះ តាមភារកិច្ចរៀង១ខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី..២២..ខែ....ធ្នូ.......ឆ្នាំ ២០១០

រដ្ឋមន្ត្រី

ច័ន្ទ-សារុន

__កន្លែងទទួល :__

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ក្រសួងបរិស្ថាន
- សាលាខេត្តក្រចេះ
- ដូចប្រការ ៧
- ឯកសារ-កាលប្បវត្តិ

## ផែនទី ទីតាំងស្នើសុំបង្កើតស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើ ព្រែកប្រសប់ ស្ថិតក្នុងស្រុកព្រែកប្រសប់ ខេត្តក្រចេះ



ព្រះរាជាណាចក្រកម្ពុជា
Kingdom of Cambodia
ជាតិ សាសនា ព្រះមហាក្សត្រ
*Nation - Religion - King*

រាជរដ្ឋាភិបាល
ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
Council for the Development of Cambodia

លេខ ៣៦៧/១១ ក.អ.ក

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ មីនា ឆ្នាំ ២០១១

# សារាចរណែនាំ
# ស្តីពី
# នីតិវិធីក្នុងការសុំពន្យារ ផ្អាក ព្យួរ ឬបញ្ឈប់សកម្មភាពវិនិយោគរបស់ក្រុមហ៊ុន

អនុលោមតាមច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សូមជំរាបជូនអ្នកវិនិយោគ ដែលពុំទាន់ និងកំពុងអនុវត្តគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ហើយ មានបំណងចង់ពន្យារ ផ្អាក ឬ ព្យួរជាបណ្តោះអាសន្ន ឬបញ្ឈប់សកម្មភាពវិនិយោគជាស្ថាពរ នូវនីតិវិធីដែលត្រូវដំណើរការ និង សំណុំបែបបទដែលត្រូវបំពេញ ដូចខាងក្រោម ៖

**១- <u>ករណីសំណើពន្យារពេលអនុវត្តរបស់អ្នកវិនិយោគពុំទាន់បានអនុវត្តគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ៖</u>**

ក្រោយពេលទទួលបាននូវឯកសារទាំងអស់ ដែលបានចេញជូនរួចរាល់ពីស្ថាប័នពាក់ព័ន្ធ រួមជាមួយវិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាពរ អ្នកវិនិយោគត្រូវដំណើរការអនុវត្តគម្រោងវិនិយោគទៅតាមកម្មវិធីការងារ ដែលសាមីក្រុមហ៊ុនបានលើកឡើងក្នុងរបាយការណ៍សមិទ្ធិលទ្ធភាពសេដ្ឋកិច្ច ដែលបានតំកល់ទុកជាផ្លូវការនៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ។

ក្រោយរយៈពេល ០៦ (ប្រាំមួយ) ខែ (លើកលែងតែករណីផ្សេងទៀត ដែលមានកំណត់ក្នុងកិច្ចសន្យាជួលដីសម្បទានសេដ្ឋកិច្ចជាមួយរដ្ឋ ឬ កិច្ចសន្យាសម្បទានផ្សេងៗ ។ល។) ប្រសិនបើ គម្រោងវិនិយោគពុំត្រូវបានអនុវត្តទេនោះ អ្នកវិនិយោគត្រូវតែលើកសំណើសុំពន្យារពេលអនុវត្តគម្រោងមកក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដោយត្រូវបញ្ជាក់ឱ្យបានច្បាស់និងមានមូលហេតុជាបង្អែកគ្រប់គ្រាន់ អំពីការសុំពន្យារពេលអនុវត្ត ដើម្បីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ពិនិត្យលើភាពចាំបាច់រួមជាមួយចំណាត់ការផ្សេងៗក្នុងការចេញលិខិតពន្យារជូនតាមសំណូមពរជាក់ស្តែង ឬធ្វើអន្តរាគមន៍ជួយអ្នកវិនិយោគដើម្បីដោះស្រាយនូវរាល់ចំណុចពាក់ព័ន្ធ ដែលជាឧបសគ្គ ឬជារបាំងនាំឱ្យរាំងស្ទះដល់ការអនុវត្តគម្រោង ។

ការពន្យារពេលត្រូវកំណត់ជូនមិនឱ្យលើសពី ០៦ (ប្រាំមួយ) ខែនោះឡើយ ។ ក្នុងករណីហួសកាលកំណត់នៃការផ្តល់ការពន្យារលើកទី០១ ហើយអ្នកវិនិយោគនៅតែពុំអាចចាប់ផ្តើមសកម្មភាពបានទៀតនោះ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា នឹងពិនិត្យសំណើអ្នកវិនិយោគសំរាប់ការពន្យារលើកទី ០២ ដោយផ្អែកលើមូលហេតុសមស្រប ។ ប៉ុន្តែការពន្យារលើកទី ០៣ នឹងមិនត្រូវបានអនុញ្ញាតឡើយ ។ លើសពីនេះ សាមីក្រុមហ៊ុនត្រូវប្រឈមនឹងការដកហូតវិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាពរ និងលប់គម្រោងចេញពីបញ្ជីវិនិយោគរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាទៀតផង ។

ឯកសារដែលត្រូវភ្ជាប់ដើម្បីសុំពន្យារពេលអនុវត្តគំរោងមាន៖

១- ពាក្យសុំពន្យារអនុវត្តគំរោង ដោយមានការបញ្ជាក់ពីមូលហេតុនៃការខកខានមិនបានអនុវត្តគំរោង

២- របាយការណ៍ស្តីពីមុខទំនិញជាវត្ថុធាតុដើម សម្ភារៈបរិក្ខារផលិតកម្ម សម្ភារៈសំណង់ ដោយពន្ធអាករនាំចូលជាបន្ទុករបស់រដ្ឋ នាពេលកន្លងមក ( ប្រសិនបើមាន)

៣- វិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាពរ និងលក្ខន្តិកៈរបស់ក្រុមហ៊ុន( ច្បាប់ថតចម្លង )

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ត្រូវធ្វើការឆ្លើយតប ទៅនឹងសំណើសុំពន្យារពេលអនុវត្តគម្រោងក្នុងរយៈពេលយ៉ាងយូរ ១០ ( ដប់) ថ្ងៃ នៃថ្ងៃធ្វើការ ក្រោយពេលទទួលបានសំណើ និងឯកសារគ្រប់គ្រាន់ពីអ្នកវិនិយោគ ។

២- <u>ករណីសំណើ សុំផ្អាក ឬព្យួរសកម្មភាពមួយរយៈរបស់អ្នកវិនិយោគដែលបានអនុវត្តគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់រួចហើយ :</u>

ក្រុមហ៊ុនត្រូវលើកសំណើជូន ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា/គណៈកម្មាធិការវិនិយោគកម្ពុជា ដោយមានបញ្ជាក់អំពីមូលហេតុ និងរយៈពេលនៃការសុំផ្អាក ឬព្យួរសកម្មភាពមួយរយៈ ដោយភ្ជាប់ជាមួយនូវឯកសារមួយចំនួនដូចខាងក្រោម :

១- ពាក្យសុំផ្អាក ឬព្យួរសកម្មភាព ដោយមានការបញ្ជាក់អំពីមូលហេតុឱ្យបានច្បាស់លាស់ និងគ្រប់គ្រាន់

២- វិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាពរ និងលក្ខន្តិកៈរបស់ក្រុមហ៊ុន( ច្បាប់ថតចម្លង )

៣- របាយការណ៍ស្តីពីមុខទំនិញជាវត្ថុធាតុដើម សម្ភារៈបរិក្ខារផលិតកម្ម សម្ភារៈសំណង់ ដោយពន្ធអាករនាំចូលជាបន្ទុករបស់រដ្ឋ នាពេលកន្លងមក ដែលមានក្នុងសន្និធិ នៅថ្ងៃផ្អាក ឬព្យួរសកម្មភាព

៤- លិខិតធានាអះអាងរក្សាទុក និងគ្រប់គ្រងឱ្យបានត្រឹមត្រូវនូវ វត្ថុធាតុដើម សម្ភារៈបរិក្ខារផលិតកម្ម សម្ភារៈសំណង់ ដូចមានក្នុងចំណុច ៣

៥- លិខិតបញ្ជាក់អំពីចំណាត់ការ ដែលបានដោះស្រាយ ជាមួយកម្មករ និយោជិត ។

ក្រោយពេលបានទទួលសំណុំបែបបទគ្រប់គ្រាន់ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា/គណៈកម្មាធិការវិនិយោគកម្ពុជា ត្រូវធ្វើការចុះពិនិត្យជាក់ស្តែងនូវស្ថានភាព ដែលអ្នកវិនិយោគបានអះអាង។ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ត្រូវធ្វើការឆ្លើយតប ទៅនឹងសំណើសុំ ផ្អាក ឬព្យួរ សកម្មភាព ក្នុងរយៈពេលយ៉ាងយូរ ១០ (ដប់) ថ្ងៃ នៃថ្ងៃធ្វើការ។ ការសុំផ្អាក ឬការព្យួរត្រូវកំណត់ជូនមិនឱ្យលើសពី ០៦ (ប្រាំមួយ) ខែឡើយ ។ ក្នុងករណីហួសកាលកំណត់នៃការផ្តល់ការអនុញ្ញាតលើកទី០១ ហើយអ្នកវិនិយោគនៅតែពុំទាន់ចាប់ផ្តើមសកម្មភាពទៀតនោះ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា នឹងពិនិត្យសំណើអ្នកវិនិយោគសំរាប់ការផ្អាកឬព្យួរលើកទី ០២ ដោយផ្អែកលើមូលហេតុសមស្រប។ ប៉ុន្តែការផ្អាក ឬព្យួរលើកទី ០៣ នឹងមិនត្រូវបានអនុញ្ញាតឡើយ ។ លើសពីនេះ សាមីក្រុមហ៊ុនត្រូវប្រឈមនឹងការដកហូតវិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាពរ និងលុបគម្រោងចេញពីបញ្ជីវិនិយោគរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាទៀតផង ក្រោយពេលក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា/គណៈកម្មាធិការវិនិយោគកម្ពុជា ចុះពិនិត្យជាក់ស្តែងឃើញថា សាមីក្រុមហ៊ុនមិនអាចបន្តសកម្មភាពបានទៀតឡើយ និងក្រោយពេលសាមីក្រុមហ៊ុន បានផ្តល់ជូននូវរាល់ឯកសារស្តីពីការជំរះកាតព្វកិច្ចពន្ធអាករគយ រួមទាំងរាល់ឯកសារស្តីពីការជំរះរាល់បំណុលពន្ធដារ ( ប្រសិនបើមាន) ។

៣- **ករណីសំណើសុំបញ្ឈប់ជាស្ថាពរនូវការអនុវត្តគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់របស់អ្នកវិនិយោគ**

ក្រៅពីករណីក្ស័យធន ដែលត្រូវអនុវត្តទៅតាមច្បាប់ស្តីពីក្ស័យធន ចំពោះសំណើបញ្ឈប់ការអនុវត្តគំរោងវិនិយោគមានលក្ខណៈ សម្បត្តិគ្រប់គ្រាន់ ទោះជាក្រៅផ្លូវតុលាការក្តី ឬ តាមផ្លូវតុលាការក្តី អ្នកវិនិយោគត្រូវ :

១- លើកសំណើជូនក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

២-ធ្វើការជំរះបញ្ជីរបស់ក្រុមហ៊ុនទាំងអស់ រួមមានប្រាក់បៀវត្សកម្មករ និយោជិត បំណុលពន្ធដារ បំណុលឯកជននានា ឱ្យបានរួចរាល់ស្របតាមនីតិវិធីនៃច្បាប់ និងបទប្បញ្ញត្តិ ស្តីពីសារពើពន្ធ ស្តីពីសហគ្រាសពាណិជ្ជកម្ម ។ ល ។

៣-ជំរះបញ្ជីពន្ធអាករគយ និង កាតព្វកិច្ចគយផ្សេងៗទៀត ដែលត្រូវបានព្យួរនាពេលនាំចូលទំនិញគ្រប់ប្រភេទក្រោមរបបព្យួរពន្ធ រាប់បញ្ចូលទាំងការនាំចូលបណ្តោះអាសន្ន ការនាំចូលដោយការលើកលែងពន្ធ និងអាករជាភាគ ឬទាំងស្រុង និង ការនាំចូលក្រោមរបបអនុគ្រោះពន្ធផ្សេងៗ ទៀត ស្របតាមច្បាប់ និងបទប្បញ្ញត្តិគយជាធរមាន ។

ការលើកសំណើសុំបញ្ឈប់សកម្មភាពវិនិយោគជាស្ថាពរ ដែលដាក់ជូនក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា/គណៈកម្មាធិការវិនិយោគកម្ពុជា ត្រូវដើរទន្ទឹមគ្នានឹងការដាក់សំណើសុំជំរះ កាតព្វកិច្ចពន្ធអាករគយ នៅអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា និងជំរះបញ្ជីពន្ធដារនៅរដ្ឋបាលសារពើពន្ធ ។

ចំពោះបែបបទ និងសំណុំលិខិតដែលត្រូវបំពេញមានៈ

**ក/បែបបទ និង សំណុំលិខិតនៃការសុំជំរះកាតព្វកិច្ចពន្ធអាករគយ នៅអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា :**

ក្រុមហ៊ុនវិនិយោគពាក់ព័ន្ធត្រូវដាក់ពាក្យសុំជំរះកាតព្វកិច្ចពន្ធអាករគយ នៅអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ( នាយកដ្ឋានរបបគយ ) រៀងរាល់ម៉ោងធ្វើការ ។ ក្នុងករណី ដែលអ្នកវិនិយោគបានផ្តល់ឯកសារគ្រប់គ្រាន់ និង ត្រឹមត្រូវ អគ្គនាយកដ្ឋានគយ និង រដ្ឋាករកម្ពុជា នឹងចេញវិញ្ញាបនប័ត្រជំរះបញ្ជីគយក្នុងរយៈពេលយ៉ាងយូរ ០៧ ( ប្រាំពីរ) ថ្ងៃ គិតចាប់ពីថ្ងៃដែលបានបំពេញកាតព្វកិច្ចគយនានា ដែលមានរួចរាល់របស់ខ្លួននោះ (ដូចមានគំរូជូនភ្ជាប់) ។ ក្នុងករណីមានការយឺតយ៉ាវណាមួយ អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ត្រូវជូនដំណឹងជាបន្ទាន់ទៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាជ្រាប ដោយបញ្ជាក់ពីមូលហេតុច្បាស់លាស់ដែលនាំឱ្យមានការយឺតយ៉ាវ ។

**ខ/បែបបបទ និង សំណុំលិខិតនៃការសុំជំរះបញ្ជីពន្ធដារនៅអគ្គនាយកដ្ឋានពន្ធដារ :** អ្នកវិនិយោគ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅរដ្ឋបាលសារពើពន្ធ ក្នុងរយៈពេល ១៥ ថ្ងៃ ក្រោយការផ្អាក ឬ បញ្ឈប់សកម្មភាពអាជីវកម្ម ដើម្បីសុំជំរះបញ្ជីពន្ធ ដោយត្រូវភ្ជាប់មកជាមួយនូវឯកសារច្បាប់ដើម នៃប័ណ្ណប៉ាតង់ វិញ្ញាបនប័ត្រអាករលើតំលៃបន្ថែម លិខិតប្រកាសពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ ឬចំណែកនៃឆ្នាំដែលបញ្ឈប់អាជីវកម្ម និងលិខិតជូនដំណឹងស្តីពីការកំណត់ពន្ធឡើងវិញ ( ឆ្នាំចុងក្រោយ) និងមានបញ្ជាក់ច្បាស់លាស់នូវឈ្មោះអភិបាល បណ្ណាធិការ អ្នកគ្រប់គ្រង ឬអ្នកតំណាងស្របច្បាប់ ដែលមានលិខិតផ្ទេរសិទ្ធិត្រឹមត្រូវ លេខអត្តសញ្ញាណកម្មសារពើពន្ធ អាស័យដ្ឋានបច្ចុប្បន្ន និង លេខទូរស័ព្ទទំនាក់ទំនង ។

ក្រោយពេលឯកសារដូចបានរៀបរាប់ខាងលើត្រូវបានបំពេញរួចរាល់ អគ្គនាយកដ្ឋានពន្ធដារនឹងធ្វើសវនកម្មជំរះបំណុលសារពើពន្ធ ចេញលិខិតបញ្ជាក់ស្ថានភាពសារពើពន្ធ (ដូចមានគំរូជូនភ្ជាប់) ក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃនៃថ្ងៃធ្វើការ ជូនអ្នកវិនិយោគ ។

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា/គណៈកម្មាធិការវិនិយោគកម្ពុជា ត្រូវចេញជូនអ្នកវិនិយោគវិញ នូវប្រកាសស្តីពីការលុបឈ្មោះក្រុមហ៊ុន និងលុបគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ក្នុងរយៈពេល ១០ (ដប់) ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីអ្នកវិនិយោគបានផ្តល់ជូននូវឯកសារដូចខាងក្រោម:

- វិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាពរ និងលក្ខន្តិកៈរបស់ក្រុមហ៊ុន (ច្បាប់ថតចម្លង)
- សេចក្តីសំរេចរបស់សមាជិកម្ចាស់ហ៊ុន ក្នុងការបញ្ឈប់ការអនុវត្តគំរោង
- វិញ្ញាបនប័ត្រជំរះកាតព្វកិច្ចពន្ធអាករគយ ចេញដោយអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា
- ឯកសារបញ្ជាក់ស្ថានភាពសារពើពន្ធ ចេញដោយអគ្គនាយកដ្ឋានពន្ធដារ
- លិខិតបញ្ជាក់អំពីស្ថានភាពបំណុលតតិយជន (កម្មករ-និយោជិត) ដែលបានជំរះ "ប្រសិនបើមាន" ។

ទទួលបានសារាចរនេះ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា/គណៈកម្មាធិការវិនិយោគកម្ពុជា អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ ស្ថាប័នពាក់ព័ន្ធ និងគ្រប់អ្នកវិនិយោគ ដែលអនុវត្តគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ទាំងអស់ មានភារកិច្ចសហការអនុវត្តឱ្យមានប្រសិទ្ធិភាពខ្ពស់នូវខ្លឹមសារនៃសារាចរណែនាំនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**
**អនុប្រធានទី ១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា**

**គាត ឈន់**

**កន្លែងទទួល**

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងមហាផ្ទៃ
-ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
-ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
-ក្រសួងពាណិជ្ជកម្ម
-ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
-ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-ក្រសួងបរិស្ថាន
-ក្រសួងទេសចរណ៍
-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**
នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ប្រធាន "ក.អ.ក"
-គ្រប់សាលាខេត្ត-រាជធានី
-សភាពាណិជ្ជកម្ម កម្ពុជា
-គ្រប់ក្រុមការងារផ្នែកឯកជន
-សមាគមកាត់ដេរ GMAC

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ២៣០០ ពណ.សបក

ភ្នំពេញថ្ងៃទី ២៧ ខែឧសភាឆ្នាំ ២០១០

# ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

## សូមបញ្ជាក់ថា :

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈស្រប តាមច្បាប់ពិការលេបរិច្ឆេទនៃការចុះបញ្ជីនេះតទៅតាមលក្ខខណ្ឌដូចខាងក្រោម

១- នាមករណ៍របស់ក្រុមហ៊ុន : **វ៉ាយ ស្តូន ត្រេឌីង**
**WHITE STONE TRADING Co., Ltd.**

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : **Co. ០៩៧១E/២០១០** ចុះថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០១០

មានទម្រង់ទ្រាយជា : ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត

២- អភិបាលក្រុមហ៊ុន : លោក LEE BAEKSUK ប្រធានក្រុមប្រឹក្សាភិបាល
លោក LEE SEUNGCHUL អភិបាល

៣- ដើមទុនក្រុមហ៊ុន : ចំនួន ២០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : ភូមិតាអុង ឃុំតាអុង ស្រុកចំការលើ ខេត្តកំពង់ចាម ។

៥- កម្មវត្ថុអាជីវកម្ម : -ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ -នាំចូលនិងនាំ សំភារៈ បរិក្ខារពេទ្យគ្រប់ប្រភេទ
-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ - ការផ្គូសផ្គុំសំភារៈ ទំនិញគ្រប់ប្រភេទ
-ប្តូរប្រាក់ កែច្នៃ ទិញ លក់គ្រឿងអលង្ការ
-មន្ទីរពេទ្យពិគ្រោះព្យាបាលជម្ងឺ
-បើកសាលារៀន
-ភ្នាក់ងារពាណិជ្ជកម្ម - តំណាងពាណិជ្ជកម្ម
-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម
-សេវារកការងារជូនអតិថិជនធ្វើក្នុង និងក្រៅប្រទេស
-សេវាផ្នែកពត៌មានវិទ្យា
-សេវាផ្សាយពាណិជ្ជកម្ម
-បោះពុម្ពផ្សាយ
-ផលិតខ្សែភាពយន្ត វីដេអូ CD
-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស - សេវាបញ្ជូន និងវេចខ្ចប់ទំនិញ
-សេវាយកកំរៃជើងសាលើការដឹកជញ្ជូន
-សាងសង់ ជួសជុល អគារ ស្ពាន ថ្នល់
-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត
-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ
-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម

៦ ថេរវេលា ៩៩ ឆ្នាំ

រាល់ដំណាច់ឆ្នាំនីមួយៗ អភិបាលក្រុមហ៊ុនមានភារកិច្ចមកដាក់របាយការណ៍ប្រចាំឆ្នាំ ដែលទាក់ទងទៅនឹងស្ថានភាព របស់ក្រុមហ៊ុននៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម ។

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬស្ថាប័នដែលគ្រប់គ្រងមុខ ជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងស្នាក់ការរបស់ក្រុមហ៊ុនពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម
រដ្ឋលេខាធិការ

គឹម_ស៊ីថន

**ចម្លងជូន**
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងកុម្មាភិបាល
- ក្រសួងទេសចរណ៍
- ក្រសួងព័ត៌មាន
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងអប់រំ យុវជន និងកីឡា
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- ក្រសួងបរិស្ថាន
- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
- សាលាខេត្តកំពង់ចាម
- មន្ទីរពាណិជ្ជកម្មខេត្តកំពង់ចាម "មុខការ"
- ឯកសារ - កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ២៣០២ ពណ.ចបព

ភ្នំពេញថ្ងៃទី២១ ខែមេសា ឆ្នាំ ២០១០

# ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

## សូមបញ្ជាក់ថា :

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅតាមលក្ខខណ្ឌដូចខាងក្រោម:

១- នាមករណ៍របស់ក្រុមហ៊ុន : **ធីជេភីភី ឌីវេឡុបមេន ថេកណូឡូជី**
**TJPP DEVELOPMENT TECHNOLOGY CO., LTD.**

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Co. ០៩៦៩KH/២០១០ ចុះថ្ងៃទី ១៥ ខែ ឧសភា ឆ្នាំ ២០១០

មានទ្រង់ទ្រាយជា : ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត

២- អភិបាលក្រុមហ៊ុន : លោក **សៃ ហេង** ប្រធានក្រុមប្រឹក្សាភិបាល
លោក WANG CHANGSONG អភិបាល

៣- ដើមទុនក្រុមហ៊ុន : ចំនួន ២០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : លេខ ៩៧ DEI ផ្លូវលេខ ២០២ សង្កាត់ទឹកល្អក់ទី៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ

៥- កម្មវត្ថុអាជីវកម្ម : -ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្ដូរទំនិញ នីហរណៈ អាហរណៈទំនិញគ្រប់ប្រភេទ -ពិសេស នាំចូលគ្រឿងអេឡិចត្រូនិចគ្រប់ប្រភេទ -នាំចូលឱសថ សំភារៈ បរិក្ខារពេទ្យគ្រប់ប្រភេទ
-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ - ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ
-ទិញ លក់ ជួល បញ្ចាំមូលនីធិពាណិជ្ជកម្ម - ទិញ លក់ ជួល ដីធ្លី ផ្ទះសំបែង
-ប្ដូរប្រាក់ កែច្នៃ ទិញ លក់គ្រឿងអលង្ការ
-មន្ទីរពេទ្យពិគ្រោះព្យាបាលជម្ងឺ
-បើកសាលារៀន
-ភ្នាក់ងារពាណិជ្ជកម្ម - តំណាងពាណិជ្ជកម្ម
-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម
-សេវារកការងារជូនអតិថិជនធ្វើក្នុង និងក្រៅប្រទេស
-សេវាផ្សាយពាណិជ្ជកម្ម
-បោះពុម្ពផ្សាយ
-ផលិតខ្សែភាពយន្ត វីដេអូ CD
-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស - សេវាបញ្ជូន និងចែកចាយទំនិញ
-សេវាយកកំរៃជើងសាលើការដឹកជញ្ជូន
-សាងសង់ ជួសជុល អគារ ស្ពាន ថ្នល់ - សិក្សាគំរោងប្លង់ និងគូរប្លង់គ្រប់ប្រភេទ
-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត
-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ
-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម

៦- ថេរវេលា : ៩៩ ឆ្នាំ

រាល់ដំណាច់ឆ្នាំនីមួយៗ អភិបាលក្រុមហ៊ុនមានកាតព្វកិច្ចមកតំកល់ប្រតិវេទន៍ប្រចាំឆ្នាំ ដែលទាក់ទងទៅនឹងស្ថានភាពរបស់ក្រុមហ៊ុននៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម ។

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬស្ថាប័នដែលគ្រប់គ្រងលើជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងស្នាក់ការរបស់ក្រុមហ៊ុនពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**
**រដ្ឋលេខាធិការ**

**គីម-ស៊ីថន**

**ចម្លងជូន**
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍
- ក្រសួងព័ត៌មាន
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងអប់រំ យុវជន និងកីឡា
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- ក្រសួងបរិស្ថាន
- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
- សាលារាជធានីភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ "មុខការ"
- ឯកសារ - កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ២៣០៣ ពណ.ចបព

ភ្នំពេញថ្ងៃទី២១ ខែឧសភា ឆ្នាំ ២០១០

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

**សូមបញ្ជាក់ថា :**

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **ឈី តឺ ខាង គ្រុប**

QI TE KANG GROUP Co., Ltd

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Co. 0៩៦៣ E/២0១0 ចុះថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ២០១០

មានទ្រង់ទ្រាយជា : ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត

២- អភិបាលក្រុមហ៊ុន : លោក CHEN SHIPING ប្រធានក្រុមប្រឹក្សាភិបាល

លោក YE BOCHAO អភិបាល

៣- ដើមទុនក្រុមហ៊ុន : ចំនួន ៤.000.000.000 រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : លេខ ៥៣៩ ផ្លូវលេខ ៧៩ K សង្កាត់កាកាប ខណ្ឌដង្កោ រាជធានីភ្នំពេញ

៥- កម្មវត្ថុអាជីវកម្ម : -ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ ពិសេសនាំចូល និងកែច្នៃថ្មម៉ាប និងថ្មក្រានីត នាំចូលគ្រឿងសំអាង គ្រឿងតុបតែងខ្លួន សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ

-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ-ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ

-ប្តូរប្រាក់ កែច្នៃ ទិញ លក់ គ្រឿងអលង្ការ

-មន្ទីរពេទ្យពិគ្រោះព្យាបាលជម្ងឺ

-បើកសាលារៀន

-ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម

-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម

-សេវាផ្សាយពាណិជ្ជកម្ម

-បោះពុម្ពផ្សាយ

-ផលិតខ្សែភាពយន្ត វីដេអូ CD

-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាបញ្ជូន និងចែកចាយទំនិញ

-សេវាយកកំរៃជើងសាលើការដឹកជញ្ជូន

-សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់

-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត

-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម ។

៦- ថេរវេលា : ៩៩ ឆ្នាំ

រាល់ដំណាច់ឆ្នាំនីមួយៗ អភិបាលក្រុមហ៊ុនមានកាតព្វកិច្ច មកតំកល់ប្រតិវេទន៍ប្រចាំឆ្នាំ ដែលទាក់ទងទៅនឹងស្ថានភាពរបស់ក្រុមហ៊ុន នៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម ។

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

រដ្ឋលេខាធិការ

គឹម_ស៊ីថន

**ចម្លងជូន**

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងបរិស្ថាន
- ក្រសួងអប់រំ យុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
- សាលារាជធានីភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ "មុខការ"
- ឯកសារ -កាលប្បវត្តិ

ស.ម

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ២៣០៤ ពណ.ចបព

ភ្នំពេញថ្ងៃទី២១ ខែ៧ ឆ្នាំ ២០១០

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

**សូមបញ្ជាក់ថា :**

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅតាមលក្ខខណ្ឌដូចខាងក្រោមៈ

១- នាមករណ៍របស់ក្រុមហ៊ុន : **អ៊ែរ ផៅវ័រ ឡូជីស្ទីក**
**AIR POWER LOGISTIC Pte., Ltd.**

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : **Co. ០៩៧៣E/២០១០** ចុះថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០១០

មានទម្រង់ទ្រាយជា : សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកម្រិត

២- អភិបាលក្រុមហ៊ុន : លោកស្រី NI MINGQIU

៣- ដើមទុនក្រុមហ៊ុន : ចំនួន ២០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ លេខ C-08 CARGO TERMINAL ផ្លូវជាតិលេខ ៤ សង្កាត់កាកាប ខណ្ឌដង្កោ រាជធានីភ្នំពេញ។

៥- កម្មវត្ថុអាជីវកម្ម : -ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ -នាំចូលឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ
-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ - ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ
-ប្តូរប្រាក់ កែច្នៃ ទិញ លក់គ្រឿងអលង្ការ
-មន្ទីរពេទ្យពិគ្រោះព្យាបាលជម្ងឺ
-បើកសាលារៀន
-ភ្នាក់ងារពាណិជ្ជកម្ម - តំណាងពាណិជ្ជកម្ម
-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម
-សេវាផ្សាយពាណិជ្ជកម្ម
-បោះពុម្ពផ្សាយ
-ផលិតខ្សែភាពយន្តវីដេអូ CD
-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស - សេវាបញ្ជូន និងចែកចាយទំនិញ
-សេវាយកកំរៃជើងសាលើការដឹកជញ្ជូន
-សាងសង់ ជួសជុល អគារ ស្ពាន ថ្នល់
-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត
-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ
-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម។

៦- ថេរវេលា : ៩៩ ឆ្នាំ

រាល់ដំណាច់ឆ្នាំនីមួយៗ អភិបាលក្រុមហ៊ុនមានកាតព្វកិច្ចមកតំកល់ប្រតិវេទន៍ប្រចាំឆ្នាំ ដែលទាក់ទងទៅនឹងស្ថានភាព របស់ក្រុមហ៊ុននៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម ។

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬស្ថាប័នដែលគ្រប់គ្រងមុខ ជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងស្នាក់ការរបស់ក្រុមហ៊ុនពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម
ជ្រេលិខិតបាធិការ
ចាម ប្រសិទ្ធ
កឹម_ស៊ីថន

**ចម្លងជូន**
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសុខាភិបាល - ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន - ធនាគារជាតិនៃកម្ពុជា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងអប់រំ យុវជន និងកីឡា
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- ក្រសួងបរិស្ថាន
- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
- សាលារាជធានីភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ "មុខការ"
- ឯកសារ - កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ២៣០៥ ពណ.ចបព

ភ្នំពេញថ្ងៃទី ២១ ខែ ១ ឆ្នាំ ២០១០

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ជំរាបមក**

លោក KIM GJEMMESTAD ប្រធានក្រុមប្រឹក្សាភិបាលក្រុមហ៊ុន **យេឡូ ថៅវ័រ**
អាសយដ្ឋាន : លេខ ១ Eo ផ្លូវសួនជ្រោយចង្វារ សង្កាត់ជ្រោយចង្វារ ខណ្ឌឫស្សីកែវ
រាជធានីភ្នំពេញ ។

**កម្មវត្ថុ** : ករណីសុំកែប្រែ និងតំកល់ទុកលក្ខន្តិកៈថ្មីរបស់ក្រុមហ៊ុន **យេឡូ ថៅវ័រ**
YELLOW TOWER Co., Ltd.

**យោង** :-សំណើរបស់ក្រុមហ៊ុន ចុះថ្ងៃទី 06 / 05 / 2010
-កំណត់ហេតុនៃអង្គប្រជុំនិងសេចក្តីសំរេចសមូហភាព ចុះថ្ងៃទី 27 / 01 / 2010
-លក្ខន្តិកៈនិងបទបញ្ជាផ្ទៃក្នុងថ្មីរបស់ក្រុមហ៊ុន ចុះហត្ថលេខា ចុះថ្ងៃទី 27 / 01 / 2010
-សេចក្តីប្រកាសស្តីពីការកែប្រែលក្ខន្តិកៈក្រុមហ៊ុនក្នុងព្រឹត្តិប័ត្រពាណិជ្ជកម្មលេខ 414
ចេញផ្សាយថ្ងៃទី 30-05-2010

តាមកម្មវត្ថុនិងយោងខាងលើ ខ្ញុំសូមជំរាបលោកថា : ក្រសួងពាណិជ្ជកម្មទទួលចុះបញ្ជីនូវការកែប្រែ និងតំកល់ទុកលក្ខន្តិកៈថ្មីរបស់ក្រុមហ៊ុន **យេឡូ ថៅវ័រ** YELLOW TOWER Co., Ltd. ដែលបានចុះបញ្ជីពាណិជ្ជកម្មក្រោមលេខ Co. 9285/06P ចុះថ្ងៃទី 29-11-2006 ទៅតាមចំណុចដូចមានចែងក្នុងលិខិតស្នើនិងយោងខាងលើគឺ :

-ការលាលែងចេញសមាជិកហ៊ុនចំនួន ០១ រូប គឺលោកស្រី **ម៉ៃ សុរ្យាទ័រ** "ប្រធានក្រុមប្រឹក្សាភិបាលចាស់"
-ការបញ្ចូលសមាជិកហ៊ុនថ្មី ០១ រូប គឺលោក **ជា ប្រុស**
-ការធ្វើអនុប្បទានភាគហ៊ុន :
-សមាសភាពសមាជិកភាគហ៊ុនថ្មី :
-លោក KIM GJEMMESTAD (សញ្ជាតិ : Norwegian ) កាន់កាប់ភាគហ៊ុនចំនួន ៤៩០ ភាគហ៊ុន
-លោក **ជា ប្រុស** (សញ្ជាតិ : ខ្មែរ ) កាន់កាប់ភាគហ៊ុនចំនួន ៥១០ ភាគហ៊ុន
-ការតែងតាំងសមាសភាពក្រុមប្រឹក្សាភិបាលថ្មី :
-លោក KIM GJEMMESTAD ប្រធានក្រុមប្រឹក្សាភិបាល
-លោក **ជា ប្រុស** អភិបាល

ប៉ុន្តែក្រុមហ៊ុនត្រូវទទួលខុសត្រូវទាំងស្រុងចំពោះមុខច្បាប់ បើប្រសិនជាមានការតវ៉ាណាមួយទាក់ទងនឹងការកែប្រែលក្ខន្តិកៈក្រុមហ៊ុននេះ ។

អាស្រ័យហេតុនេះ សូមលោកជ្រាប និងអនុវត្តតាមការសមស្រប ។

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**រដ្ឋលេខាធិការ**

**គឹម_ស៊ីថន**

ចម្លងជូន :

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ធនាគារជាតិ នៃកម្ពុជា
- ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- ក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និង នេសាទ
- អគ្គនាយកដ្ឋានរាជកិច្ច និង សេវាកុំព្យូទ័រ
- សាលារាជធានីភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ " មុខការ "
- ឯកសារ - កាលប្បវត្តិ

ស.ផ

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

**ក្រសួងពាណិជ្ជកម្ម**
Ministry of Commerce
លេខ ២៣០៩ ពណ.ចបព

ភ្នំពេញថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០១០

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម
## ជំរាបមក

លោក **សុត គីមសេង** ប្រធានក្រុមប្រឹក្សាភិបាលក្រុមហ៊ុន **ចាង លី អេង ខូ អិលធីឌី**
អាស័យដ្ឋាន : លេខ ៤៧៧ ផ្លូវលេខ ២៥០ សង្កាត់បឹងព្រលិត ខណ្ឌ៧មករា រាជធានីភ្នំពេញ ។

**កម្មវត្ថុ :** ករណីសុំកែប្រែ និងតំកល់ទុកលក្ខន្តិកៈថ្មីរបស់ក្រុមហ៊ុន **ចាង លី អេង ខូ អិលធីឌី** JANG LI ENG Co., Ltd.

**យោង :** -សំណើរបស់ក្រុមហ៊ុន ចុះថ្ងៃទី 10 / 05 / 2010
-កំណត់ហេតុនៃអង្គប្រជុំ និងសេចក្តីសំរេចសមូហភាព ចុះថ្ងៃទី 30 / 04 / 2010
-លក្ខន្តិកៈនិងបទបញ្ជាផ្ទៃក្នុងថ្មីរបស់ក្រុមហ៊ុន ចុះហត្ថលេខា ចុះថ្ងៃទី 10 / 05 / 2010
-សេចក្តីប្រកាសស្តីពីការកែប្រែលក្ខន្តិកៈក្រុមហ៊ុនក្នុងព្រឹត្តិប័ត្រពាណិជ្ជកម្មលេខ 414 ចេញផ្សាយថ្ងៃទី 30/05/2010

តាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជំរាបលោកថា : ក្រសួងពាណិជ្ជកម្មទទួលចុះបញ្ជីនូវការកែប្រែលក្ខន្តិកៈក្រុមហ៊ុន **ចាង លី អេង ខូ អិលធីឌី** JANG LI ENG Co., Ltd. ដែលបានចុះបញ្ជីពាណិជ្ជកម្មក្រោមលេខ Co. 6235/09 E ចុះថ្ងៃទី 28 / 10 / 2009 ទៅតាមចំណុចដូចមានចែងក្នុងលិខិតស្នើ និងយោងខាងលើគឺ :

-ការប្តូរទីស្នាក់ការក្រុមហ៊ុន :
-ទីស្នាក់ការចាស់ : លេខ ៤៥ ផ្លូវលេខ ៦៣ សង្កាត់បឹងកេងកងទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ
ប្តូរមកទីស្នាក់ការថ្មី : លេខ ៤៧៧ ផ្លូវលេខ ២៥០ សង្កាត់បឹងព្រលិត ខណ្ឌ៧មករា រាជធានីភ្នំពេញ ។

-ការបញ្ចូលសមាជិកភាគហ៊ុនថ្មីចំនួន ០១ រូប : គឺ លោក **សុត គីមសេង**

-ការធ្វើអនុប្បទានភាគហ៊ុន

-សមាសភាពសមាជិកភាគហ៊ុនថ្មី :
-លោក **សុត គីមសេង** (សញ្ជាតិ ខ្មែរ) កាន់កាប់ភាគហ៊ុនចំនួន ០៥០ ភាគហ៊ុន
-លោក LEE SUNG WOOK (សញ្ជាតិ កូរ៉េ) កាន់កាប់ភាគហ៊ុនចំនួន ៤៤០ ភាគហ៊ុន
-លោក ZHANG XIAO BO (សញ្ជាតិ ចិន) កាន់កាប់ភាគហ៊ុនចំនួន ៥១០ ភាគហ៊ុន

-ការតែងតាំងសមាសភាពក្រុមប្រឹក្សាភិបាលថ្មី :
-លោក **សុត គីមសេង** ប្រធានក្រុមប្រឹក្សាភិបាល
-លោក LEE SUNG WOOK អភិបាល
-លោក ZHANG XIAO BO "ប្រធានក្រុមប្រឹក្សាភិបាលចាស់" អភិបាល

ប៉ុន្តែក្រុមហ៊ុនត្រូវទទួលខុសត្រូវទាំងស្រុងចំពោះមុខច្បាប់ បើប្រសិនជាមានការតវ៉ាណាមួយទាក់ទងនឹងការកែប្រែលក្ខន្តិកៈក្រុមហ៊ុននេះ ។

អាស្រ័យហេតុនេះ សូមលោកជ្រាប និងអនុវត្តស្របទៅតាមច្បាប់ជាធរមាន ។

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**រដ្ឋលេខាធិការ**

**គឹម_ស៊ីថន**

**ចម្លងជូនៈ**

-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
-ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
-ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា
-ធនាគារជាតិ នៃកម្ពុជា
-ក្រសួងសុខាភិបាល
-ក្រសួងទេសចរណ៍
-ក្រសួងពត៌មាន
-ក្រសួងបរិស្ថាន
-ក្រសួងអប់រំយុវជន និងកីឡា
-ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ
-ក្រសួងសាធារណការ និង ដឹកជញ្ជូន
-រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
-ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
-ក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និង នេសាទ
-អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
-សាលារាជធានីភ្នំពេញ
-មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ "មុខការ"
-ឯកសារ - កាលប្បវត្តិ

ទ.ស.រ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ [illegible] ពណ.ចបព

ភ្នំពេញថ្ងៃទី ២៧ ខែ [illegible] ឆ្នាំ [illegible] 10

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

**សូមបញ្ជាក់ថា :**

សាខាក្រុមហ៊ុនបរទេសមួយត្រូវបានចុះបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : NTT COMMUNICATIONS ( THAILAND ) CO., LTD.

នាមករណ៍របស់សាខា : **សាខាក្រុមហ៊ុន អិនធីធី ខមមូនីខេសិន (ថៃឡែន) ខូ អិលធីឌី**

**Branch of NTT COMMUNICATIONS ( THAILAND ) CO., LTD**

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Co. ០០២១ Br /២០១០ ចុះថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០១០

២- អភិបាលសាខាក្រុមហ៊ុន : លោក JUNICHI OKA

៣- ទីស្នាក់ការសាខា : ភ្នំពេញសេនធើរ ប្លុក F ជាន់ទី៦ បន្ទប់លេខ៦៨៦ វិថីព្រះសីហនុ កែង វិថីសម្តេចសុធារស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ

៤- កម្មវត្ថុអាជីវកម្ម : -នីហរណ៍ អាហរណ៍ ទិញ លក់ ជួលសំភារៈបរិក្ខារទូរគមនាគមន៍ -ផ្តល់សេវាពិគ្រោះយោបល់ និងសេវាបច្ចេកវិទ្យាផ្នែកទូរគមនាគមន៍ -ផ្តល់សេវារៀបចំតម្លើងជួសជុល និងថែទាំបណ្តាញទូរគមនាគមន៍-សេវាផ្នែកពត៌មានវិទ្យា-អ៊ិនធើណេត -សេវាបណ្តុះបណ្តាលមុខវិជ្ជាជីវៈខាងផ្នែកទូរគមនាគមន៍ ។

៥- សញ្ជាតិក្រុមហ៊ុន : ថៃ

រាល់ដំណាច់ឆ្នាំនីមួយៗអភិបាលក្រុមហ៊ុនមានកាតព្វកិច្ច មកតំកល់ប្រតិវេទន៍ប្រចាំឆ្នាំ ដែលទាក់ទងទៅនឹងស្ថានភាពរបស់ក្រុមហ៊ុន នៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្មនៃក្រសួងពាណិជ្ជកម្ម ។

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់សាខា ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**
**ជ.រដ្ឋលេខាធិការ**

**គឹម_ស៊ីថន**

**ចម្លងជូន:**

- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា -ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ -ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- ក្រសួងពត៌មាន -អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
- សាលារាជធានីភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ "មុខការ"
- ឯកសារ -កាលប្បវត្តិ

ស.ម

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

**ក្រសួងពាណិជ្ជកម្ម**
Ministry of Commerce
លេខ ២៣៥៣ ពណ.ចបព

ភ្នំពេញថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០១០

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម
### សូមបញ្ជាក់ថា :

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅតាមលក្ខខណ្ឌដូចខាងក្រោម :

| | | | |
|---|---|---|---|
| ១- នាមករណ៍របស់ក្រុមហ៊ុន | : | **ស៊ុន អាម អេនជីនារីង & ខនស្ត្រាក់សិន**<br>SUN AM ENGINEERING & CONSTRUCTION Co., Ltd. | |
| អត្តលេខចុះបញ្ជីពាណិជ្ជកម្ម | : | Co. ០៩៧៥E/២០១០ | ចុះថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០១០ |
| មានទ្រង់ទ្រាយជា | : | ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត | |
| ២- អភិបាលក្រុមហ៊ុន | : | លោក CHANG JAE SUN | ប្រធានក្រុមប្រឹក្សាភិបាល |
| | | លោក CHOI JIHO | អភិបាល |
| | | លោក HONG SEUNG GEOL | អភិបាល |
| ៣- ដើមទុនក្រុមហ៊ុន | : | ចំនួន ២.០០០.០០០.០០០ រៀល | |
| ៤- ទីស្នាក់ការក្រុមហ៊ុន | : | លេខ ៦៨ B ផ្លូវលេខ ២៩៤ សង្កាត់បឹងកេងកងទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ។ | |

៥- កម្មវត្ថុអាជីវកម្ម :
- -សាងសង់ ជួសជុល អគារ ស្ពាន ថ្នល់ -សិក្សាគំរោងប្លង់ និងគូរប្លង់គ្រប់ប្រភេទ
- -ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ -នាំចូលឱសថ សំភារៈ បរិក្ខារពេទ្យគ្រប់ប្រភេទ
- -ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ - ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ
- -ប្តូរប្រាក់ កែច្នៃ ទិញ លក់គ្រឿងអលង្ការ
- -មន្ទីរពេទ្យពិគ្រោះព្យាបាលជម្ងឺ
- -បើកសាលារៀន
- -ភ្នាក់ងារពាណិជ្ជកម្ម - តំណាងពាណិជ្ជកម្ម
- -សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម
- -សេវារកការងារជូនអតិថិជនធ្វើក្នុង និងក្រៅប្រទេស
- -សេវាផ្សាយពាណិជ្ជកម្ម
- -បោះពុម្ពផ្សាយ
- -ផលិតខ្សែភាពយន្ត វីដេអូ CD
- -ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស - សេវាបញ្ជូន និងចែកចាយទំនិញ
- -សេវាយកកំរៃជើងសាលើការដឹកជញ្ជូន
- -ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត
- -វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ
- -វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម។

៦- ថេរវេលា ៩៩ ឆ្នាំ

រាល់ដំណាច់ឆ្នាំនីមួយៗ អភិបាលក្រុមហ៊ុនមានកាតព្វកិច្ចមកតំកល់ប្រតិវេទន៍ប្រចាំឆ្នាំ ដែលទាក់ទងទៅនឹងស្ថានភាព របស់ក្រុមហ៊ុននៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម ។

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬស្ថាប័នដែលគ្រប់គ្រងមុខ ជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងស្នាក់ការរបស់ក្រុមហ៊ុនពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម
រដ្ឋលេខាធិការ

ភឹម_ស៊ីថន

**ចម្លងជូន**

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍
- ក្រសួងព័ត៌មាន
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងអប់រំ យុវជន និងកីឡា
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- ក្រសួងបរិស្ថាន
- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- អគ្គនាយកដ្ឋានរាជកិច្ច និងសោភ័ណ្ឌទ័រ
- សាលារាជធានីភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ "មុខការ"

រប.រប.រ - ឯកសារ - កាលប្បវត្តិ